មេរៀនទី ៤

បញ្ហានៅក្នុងការទំនាក់ទំនងសង្គម

ពេលខ្លះ យើងបានឮអំពីរឿងដែលអគ្គរដ្ឋទូតបរទេសដែលត្រូវបង្គាប់ឲ្យត្រឡប់ទៅប្រទេសគេវិញ ដោយមានទំនាស់រវាងប្រទេសរបស់គាត់ ជាមួយនឹងប្រទេសដែលគាត់បម្រើការជាតំណាងសម្រាប់ប្រទេសរបស់គាត់។ មានពេលខ្លះ ដែលអគ្គរដ្ឋទូតត្រូវបានគេសម្លាប់ដោយសារតែជម្លោះបែបនេះ។ សំណាងល្អ រឿងទាំងនេះ គ្រាន់តែជាលក្ខខណ្ឌពិសេស មិនមែនជាច្បាប់នោះទេ។ ភាគច្រើន អគ្គរដ្ឋទូតរវាងប្រទេសសន្តិភាពពីរ គឺត្រូវបានគេគោរព និង លើកតម្កើងទុកជា អ្នកមានសិទ្ធិអំណាចតំណាងឲ្យប្រទេសរបស់ពួកគេ ហើយអាកប្បកិរិយារបស់ពួកគេ បាននាំឲ្យមានការលើកតម្កើង និង ការគោរពសម្រាប់ប្រទេសរបស់ពួកគេ។

តើអ្នកដឹងទេថា អ្នកគឺជាអគ្គរាជទូតយ៉ាងដូច្នោះដែរ? អ្នកគឺជាប្រជាជននៅក្នុងអាណាចក្រនៃស្ថានបរមសុខ ដូច្នេះហើយ អ្នកជាតំណាងរបស់មហាក្សត្រនៃអាណាចក្រនោះ គឺព្រះអម្ចាស់ព្រះយេស៊ូគ្រិស្តនៅលើផែនដីនេះ។ តាំងពីដើមដំបូងបង្អស់នៃប្រវត្តិសាស្ត្ររបស់មនុស្សជាតិ បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ គឺនាំមនុស្សជាតិឲ្យមានទំនាក់ទំនងកាន់តែជិតស្និទ្ធជាមួយទ្រង់ម្តងទៀត។ ប៉ុន្តែ សេចក្តីពិតដ៏អស្ចារ្យនោះគឺ ឥឡូវនេះ "ព្រះអង្គក៏ដាក់ព្រះបន្ទូលនៃការសំរុះសំរួល [ឲ្យត្រូវគ្នាវិញ]នេះមកក្នុងយើងដែរ។ ដូច្នេះ យើងជារាជទូតរបស់ព្រះគ្រិស្ត គឺដូចជាព្រះជាម្ចាស់មានព្រះបន្ទូលដាស់តឿនបងប្អូន តាមរយៈយើងដែរ។" (គម្ពីរ២កូរិនថូស ៥:១៩-២០)។

វាប្រហែលជាងាយស្រួលសម្រាប់យើងជាង ក្នុងការប្រឈមមុខជាមួយនឹងបញ្ហានៅក្នុងការទំនាក់ទំនងសង្គម នៅកន្លែងធ្វើការ នៅសាលា នៅក្នុងក្រុមជំនុំ នៅសហគមន៍របស់យើង ប្រសិនបើយើងអាចផ្តោតសំខាន់ថា យើងជានរណា ហើយយើងជាកម្មសិទ្ធិរបស់អ្នកណានោះ! នៅក្នុងមេរៀននេះ យើងនឹងមើលទៅលើបញ្ហាធំៗខ្លះ នៅក្នុងពន្លឺនៃទំនាក់ទំនងរបស់យើងជាមួយនឹងព្រះគ្រិស្ត ហើយតាមរយៈទ្រង់ផងដែរ យើងមើលពីទំនាក់ទំនងរបស់យើងជាមួយអ្នកដែលមិនស្គាល់ទ្រង់ និង អ្នកដែលទទួលការជំរុញចិត្តពីបំណងប្រាថ្នាដ៏អាត្មានិយម។ តើគ្រិស្តបរិស័ទត្រូវប្រឈមមុខជាមួយនឹងបញ្ហាទាំងនេះ ដែលជាផ្នែកមួយនៃបទពិសោធន៍ប្រចាំថ្ងៃរបស់យើងបាន ដោយរបៀបណា? ព្រះគម្ពីរបានផ្តល់ការណែនាំល្អៗសម្រាប់របៀបដោយយើងគួរតែ *ធ្វើ* និង *ឆ្លើយតប* ។សូមអនុញ្ញាតឲ្យព្រះគម្ពីរបានឆ្លើយតបចំពោះតម្រូវការរបស់អ្នក ស្របពេលដែលអ្នកសិក្សាមេរៀនមួយនេះ។

គម្រោងមេរៀន

ក. ភាពលោភលន់

ខ. បំណងចង់បានឋានៈ

គ. ភាពក្មេងខ្ចីរបស់គ្រិស្តបរិស័ទ

ឃ. ភាពមានបាន និង ភាពក្រីក្រ

ង. ភាពអយុត្តិធម៌

វត្ថុបំណងមេរៀន

នៅពេលដែលអ្នកបញ្ចប់មេរៀននេះអ្នកអាចនឹង៖

១. វាយតម្លៃឥរិយាបថរបស់អ្នក ដើម្បីកំណត់ថាអ្នកមានបញ្ហាជាមួយនឹងភាពលោភលន់ ឬទេ។

២. ស្គាល់សេចក្តីបង្រៀនរបស់ព្រះយេស៊ូ ទាក់ទងនឹងរបៀបយកឈ្នះបំណងចង់បានឋានៈ។

៣. រកឃើញដំណោះស្រាយសម្រាប់ភាពក្មេងខ្ចីរបស់គ្រិស្តបរិស័ទ នៅក្នុងគម្ពីរអេភេសូជំពូក ៤ និង ជំពូក៥ ហើយសរសេរដំណោះស្រាយទាំងនោះនៅក្នុងតារាងមួយ។

៤. ជ្រើសរើសប្រយោគដែលបកស្រាយបានយ៉ាងត្រឹមត្រូវ អំពីប្រភពដែលអាចឲ្យយើងមានភាព ពេញវ័យនៅក្នុងព្រះគ្រិស្ត។

៥. ស្គាល់ដំណោះស្រាយនៅក្នុងព្រះគម្ពីរសម្រាប់បញ្ហាដែលទាក់ទងនឹង ភាពមានបាន និង ភាព ក្រីក្រ។

៦. ស្វែងរក និង កែកំហុសនៅក្នុងពាក្យមួយឃ្លាដែលនិយាយទាក់ទងនឹងគុណតម្លៃរបស់គ្រិស្តបរិស័ទ ជាមួយនឹងបញ្ហាលុយ។

៧. ថ្លែងពីគោលការណ៍ដែលគួរតែដឹកនាំ ការឆ្លើយរបស់គ្រិស្តបរិស័ទម្នាក់ ដែលជាជនរងអំពើ អយុត្តិធម៌។

សកម្មភាពនៃការសិក្សា

១. សិក្សាមេរៀននេះទៅតាមការណែនាំ ដែលបានផ្តល់ជូននៅក្នុងសកម្មភាពនៃការសិក្សានៅក្នុង មេរៀនទី១។ ចូរឆ្លើយ សំណួរសិក្សានីមួយៗឲ្យអស់មុនពេល អ្នកមើលចម្លើយដែលយើងបាន ផ្តល់ជូននៅចុងបញ្ចប់នៃមេរៀន។

២. នៅក្នុងមេរៀននេះ មានបទគម្ពីរយោងសំខាន់ៗជាច្រើន។ ចូរអានបទគម្ពីរនីមួយៗដោយយក ចិត្តទុកដាក់នៅក្នុងព្រះគម្ពីររបស់អ្នក។

៣. ចូរសិក្សាពាក្យសំខាន់ និង និយមន័យរបស់វាផងដែរ។

៤. ធ្វើការប្រឡងផ្ទាល់ខ្លួន ហើយពិនិត្យមើលចម្លើយរបស់អ្នក។

ពាក្យសំខាន់

ភាពបោកប្រាស់	អយុត្តិធម៌	ឋានៈ
ចិត្តសប្បុរស	អាសអាភាស	អ្នកបម្រើ
សេចក្តីលោភលន់	ភាពក្រីក្រ	ឧត្តមភាព
ក្មេងខ្ចី	ការប្រមាថ	ថោកទាប
ភាពតូចទាប	ការបណ្តោយខ្លួន	

ក. ភាពលោភលន់

វត្ថុបំណងទី១. *វាយតម្លៃឥរិយាបថរបស់អ្នក ដើម្បីកំណត់ថាអ្នកមានបញ្ហាជាមួយនឹងភាពលោភលន់ ឬទេ។*

យើងរស់នៅក្នុងពិភពលោកដែលរួបរួមគ្នា។ ខ្ញុំមានន័យថា ពិភពលោករបស់យើងគឺបង្កើតឡើងពីសហគមន៍ដែលមានមនុស្សរស់នៅ ធ្វើការងារ លេងកំសាន្ត និង ទាក់ទងគ្នាទៅវិញទៅមកតាមរបៀបផ្សេងៗជាច្រើន។ បុគ្គលគ្រប់រូបនៅក្នុងពិភពលោកនេះ ទទួលបានសិទ្ធិក្នុងការសម្រេចចិត្តដោយខ្លួនគេ។ មនុស្សគ្រប់រូប បានទទួលស្នងនិស្ស័យមួយដែលហាក់បីដូចជា មានទំនោរឆ្ពោះទៅរក ភាពអាត្មានិយម មហិច្ឆតា ការផ្តាប់បំណងផ្ទាល់ខ្លួន និង បំណងចង់ឲ្យមនុស្សគ្រប់រូបកោតសរសើរ។ ដូច្នេះ មិនចាំបាច់ឆ្ងល់ទេថា ហេតុអ្វីបានជាយើងបង្កបញ្ហាឲ្យគ្នាទៅវិញទៅមកច្រើនម្ល៉េះ ដោយសារតែអាកប្បកិរិយាខុសឆ្គងនោះ។

បញ្ហាដ៏ធំមួយនៅក្នុងទំនាក់ទំនងរបស់យើងជាមួយនឹងអ្នកដទៃ គឺ ភាពលោភលន់ ឬ សេចក្តីលោភ ដែលជាការចង់បានអ្វីជារបស់អ្នកដទៃ។ យើងចង់បានអំណាច ទ្រព្យ តំណែង មិត្តភក្តិ ភាពទាក់ទាញ និង ទេពកោសល្យរបស់នរណាម្នាក់ យើងចង់បានអ្វីៗដែលល្អបំផុតសម្រាប់ខ្លួនឯង ទោះបីជាមានការខាតបង់របស់អ្នកដទៃក៏ដោយ។ ក្រឹត្យវិន័យចុងក្រោយ ក្នុងក្រឹត្យវិន័យទាំងដប់ប្រការ គឺជាការព្រមានយ៉ាងធ្ងន់ៗ ទាស់នឹងការនេះ៖

> កុំលោភលន់ចង់បានផ្ទះរបស់អ្នកដទៃ កុំលោភលន់ចង់បានប្រពន្ធគេ ឬក៏លោភលន់ចង់បានអ្នកបំរើប្រុស អ្នកបំរើស្រី គោ លា ឬអ្វីផ្សេងទៀតដែលជារបស់គេឡើយ។
> (គម្ពីរនិក្ខមនំ ២០:១៧)

តើអ្នកតែងតែប្រៀបធៀបខ្លួនឯង ទៅនឹងអ្នកដទៃ និង ភាពជោគជ័យរបស់គេមែនឬទេ? ការនេះអាចជួយអ្នកនៅក្នុងប្រការមួយចំនួន ប៉ុន្តែវាអាចនឹងគ្រោះថ្នាក់ប្រសិនបើវា ធ្វើឲ្យអ្នកជ្រួលច្របល់ និង មិនពេញចិត្ត គ្រប់ពេល។ តើអ្នកគួរតែព្យាយាមបន្តធ្វើតាមមនុស្សគ្រប់គ្នាដែលអ្នកកោតសរសើរដែរឬទេ? មិនចាំបាច់នោះទេ ។ ប្រាកដណាស់ អ្នកអាចរៀនពីអ្នកដទៃបាន។ មនុស្សយើងសុទ្ធតែធ្វើដូច្នេះទាំងអស់គ្នា។ ប៉ុន្តែ ក្នុងពេលជាមួយគ្នានោះដែរ អ្នកគួរតែដឹងពីដែនកំណត់របស់អ្នក និង ទទួលស្គាល់ថាខ្លួនឯងជានរណា។ អ្នកក៏ត្រូវដឹងពីកម្លាំងរបស់ខ្លួន ហើយអភិវឌ្ឍវាឲ្យបានពេញលេញ ប៉ុន្តែកុំស្វែងរកធ្វើកិច្ចការណាដែលមិនអាចធ្វើបាន!

ខ្ញុំអាចរីករាយជាមួយនឹង អ្នកលេងវីយូឡុងក្នុងការប្រគុំតន្ត្រីមួយ ដោយមិនចាំបាច់ត្រូវធ្វើជាតន្ត្រីករ ឬ តូចចិត្តជាមួយនឹងតន្ត្រីករនោះទេ។ ខ្ញុំអាចកោតសរសើរ ផ្ទះ ឡាន ឬ កង់របស់អ្នកជិតខាងខ្ញុំ ហើយខ្ញុំអាចត្រេកអរជាមួយគាត់ដោយមិនចាំបាច់ត្រូវធ្វើដូចគាត់នោះទេ។ ព្រះគម្ពីរបានបង្រៀនថា យើងគួរតែ "ចូរអរសប្បាយជាមួយអស់អ្នកដែលអរសប្បាយ ចូរយំសោកជាមួយអស់អ្នកដែលយំសោក" (គម្ពីររ៉ូម១២:១៥) ។ ការអាណិតនរណាម្នាក់គឺមិនពិបាកទេ ប៉ុន្តែពេលខ្លះ ការអរសប្បាយជាមួយនរណាម្នាក់ គឺពិបាកណាស់ ជាពិសេសប្រសិនបើអ្នកមានអារម្មណ៍ច្រណែន។

ភាពលោភលន់ អាចនាំឲ្យមានអំពើបាបដែលបង្កឲ្យមានបញ្ហាផ្សេងទៀតដូចជា៖ ការកុហស ឬ ការលួចដើម្បីបានអ្វីដែលអ្នកចង់បាន ការខឹង ការប៉ះពាល់ដល់ទីបន្ទាល់ជាគ្រិស្តបរិស័ទរបស់អ្នក ការច្រណែន ការថ្នាំងថ្នាក់ក្នុងចិត្ត ការស្អប់ ការសងសឹក ការបោកបន្លំ... ដូច្នេះហើយបានជាព្រះជាម្ចាស់បញ្ចូល ការព្រមានទាក់ទងនឹងភាពលោភលន់ នៅក្នុងក្រឹត្យវិន័យទាំងដប់ប្រការនោះ។

លំហាត់អនុវត្តន៍

១ នៅក្នុងមេរៀនទី២ យើងបានពិភាក្សាអំពីដំណោះស្រាយមួយដែលយើងអាចធ្វើបាន សម្រាប់បញ្ហាទាក់ទងនឹងភាពលោភលន់។ ចូរប្រាប់ថា ដំណោះស្រាយជាអ្វី និង ចូរប្រាប់ពីបទគម្ពីរយោងដែលគាំទ្រដំណោះស្រាយនោះផងដែរ។

....

២ ចូរអ្នកសាកល្បងខ្លួនឯង។ ប្រសិនបើចម្លើយរបស់អ្នកគឺ បាទ/ចាស នៅក្នុងសំណួរណាមួយ អ្នកត្រូវតែយកជំហាននៃការដោះស្រាយបញ្ហាមកអនុវត្តនៅក្នុងបញ្ហាភាពលោភលន់របស់អ្នក ហើយទូលសូមឲ្យព្រះជាម្ចាស់ ឲ្យជួយអ្នកបង្វែរបញ្ហានោះឲ្យទៅជា ឥរិយាបថនៃក្តីស្រឡាញ់វិញ។ អ្នកត្រូវជំនួសអក្សរ X ដោយឈ្មោះមនុស្ស ប្រសិនបើស្ថានភាពនោះត្រូវនឹងស្ថានភាពរបស់អ្នក។

		បាទ/ចាស	ទេ
ក)	ខ្ញុំមានមិត្តភក្តិម្នាក់ដែលហាក់បីដូចជា ជោគជ័យគ្រប់អ្វីៗទាំងអស់ដែលគេធ្វើ ហើយខ្ញុំមានអារម្មណ៍ថាតូចទាបណាស់នៅចំពោះគាត់។		
ខ)	ខ្ញុំមិនពេញចិត្តនឹងទេពកោសល្យដែលខ្ញុំមាននោះទេ ហើយខ្ញុំតែងតែប្រាថ្នា ចង់មានទេពកោសល្យដូច "X" ដែរ។		
គ)	ខ្ញុំនឿយហត់នឹងភាពក្រីក្រណាស់។ ខ្ញុំប្រាថ្នាថា ខ្ញុំមានរបស់ល្អជាច្រើនដូច "X" ដែរ។		
ឃ)	ខ្ញុំមានសិទ្ធិ ច្រណែននឹង "X" ដ្បិតចៅហ្វាយ ឬ ប្រធានរបស់ខ្ញុំ តែងតែធ្វើល្អជាមួយគាត់ ជាងជាមួយខ្ញុំ។		
ង)	ខ្ញុំខឹងព្រះជាម្ចាស់ណាស់ ព្រោះខ្ញុំហាក់បីដូចជាទទួលបានការអាក្រក់គ្រប់រឿងទាំងអស់ ខណៈពេលដែលមិត្តរបស់ខ្ញុំ គេតែងតែមានអ្វីៗគ្រប់យ៉ាងដែលគេចង់បាន ឬ ត្រូវការ។		

	បាទ/ចាស	ទេ
ច) នៅពេលដែលមិត្តរួមការងាររបស់ខ្ញុំម្នាក់ត្រូវបានគេស្ដីបន្ទោស ដោយសារតែបានធ្វើកំហុសមួយ វាធ្វើឲ្យខ្ញុំពេញចិត្តយ៉ាងខ្លាំង។		
ឆ) "X" មានរបស់មួយដែលខ្ញុំចង់បានខ្លាំងណាស់ ដែលខ្ញុំមិនអាចគិតពីអ្វីផ្សេងទៀតបានទេ។		

ខ. បំណងចង់បានឋានៈ

វត្ថុបំណងទី២. *ស្គាល់សេចក្ដីបង្រៀនរបស់ព្រះយេស៊ូ ទាក់ទងនឹងរបៀបយកឈ្នះបំណងចង់បានឋានៈ។*

មានមនុស្សម្នាក់ធ្លាប់បាននិយាយថា៖ "ពិភពលោកមិនទាន់បានឃើញពីអ្វី ដែលមនុស្សមិនខ្វល់ពីការស្វែងរកគុណសម្បត្តិសម្រាប់ខ្លួន អាចធ្វើសម្រាប់ព្រះរាជ្យរបស់ព្រះជាម្ចាស់នៅឡើយនោះទេ។"

និស្ស័យជាមនុស្សរបស់យើង គឺចង់ឲ្យអ្នកដទៃកត់សំគាល់ ចង់ទទួលបានការលើកតម្កើង តំណែង ការកោតសរសើរ ឋានៈ ការទទួលស្គាល់ និង អំណាច។ តើអ្នកធ្លាប់មានអារម្មណ៍ឈឺចាប់ ដោយសារតែអ្នកមិនទទួលបាន ការទទួលស្គាល់ដ៏សមរម្យចំពោះអ្វីដែលអ្នកបានធ្វើ ដែរឬទេ? ខ្ញុំធ្លាប់មានអារម្មណ៍បែបនេះ។ ប្រហែលមនុស្សគ្រប់គ្នា សុទ្ធតែធ្លាប់មានអារម្មណ៍បែបនេះ នៅពេលណាមួយ។ បញ្ហា កើតចំពោះមនុស្សដែលតែងតែស្រេកឃ្លានចង់ខ្ពស់ជាងគេ ចំពោះអ្នកដែលចង់គ្រប់គ្រង និង ចង់ទទួលបានគុណសម្បត្តិសម្រាប់អ្វីដែលគេធ្វើបានសម្រេច។ បញ្ហាក៏កើតឡើងចំពោះមនុស្សដែលមានអារម្មណ៍ច្រណែន នៅពេលដែលអ្នកដទៃទទួលបានការកោតសរសើរ និង ទទួលស្គាល់ ឬ ចំពោះមនុស្សដែលថ្នាំងថ្នាក់ចិត្តនៅពេលដែលការធ្វើទានរបស់គេ មិនត្រូវបានគេមើលឃើញ។

ប៉ុន្តែព្រះយេស៊ូ មានឱសថសម្រាប់ព្យាបាលការឈឺចាប់ប្រភេទនេះ ព្រមទាំងរឿងគ្រោះថ្នាក់ផ្សេងទៀតដែលទាក់ទងនឹង ការស្វែងរកឋានៈផងដែរ។ ឱសថសម្រាប់ព្យាបាលនោះគឺមាននៅក្នុងយើង។ វាគឺជាឥរិយាបថដែលយើងបម្រើព្រះជាម្ចាស់។

ព្រះយេស៊ូបានជ្រាបពីអ្វីដែលនៅក្នុងមនុស្សម្នាក់ (គម្ពីរយ៉ូហាន ២:២៤-២៥) ។ ទ្រង់បានជ្រាបអំពីទំនោររបស់យើង ដែលមានអារម្មណ៍ច្រណែន និង មានបំណងចង់បានអំណាច។ នៅគ្រាដែលទ្រង់គង់នៅជាមួយពួកសាវ័ករបស់ទ្រង់នៅឡើយ ពួកគេបានប្រកែកគ្នាអំពីនរណាដែលនៅក្នុងចំណោមពួកគេដែលល្អជាងគេបង្អស់ (គម្ពីរលូកា ២២:២៤) ។ ទ្រង់បានមានបន្ទូលប្រាប់ពួកគេ កុំឲ្យធ្វើដូចជាពួកស្ដេចដែលគ្មានសាសនា ដែលស្វែងរកអំណាច ហើយចង់សង្កត់សង្កិនមនុស្សដែលនៅក្រោមអំណាចរបស់ពួកគេ។ ទ្រង់មានព្រះបន្ទូលថា "ក្នុងចំណោមអ្នករាល់គ្នា អ្នកដែលធំជាងគេ ត្រូវធ្វើតូចជាងគេ ហើយអ្នកដែលដឹកនាំគេ ត្រូវបំរើគេវិញ។" (គម្ពីរលូកា ២២:២៥-២៦) ។

ព្រះយេស៊ូបានបង្ហាញពួកគេ ដោយទ្រង់ធ្វើជាគំរូសម្រាប់អ្វីដែលទ្រង់មានព្រះបន្ទូល ដោយការធ្វើជាអ្នកបម្រើម្នាក់។ នៅពេលបរិភោគអាហារចុងក្រោយក្នុងថ្ងៃបុណ្យចម្លង ព្រះយេស៊ូបានលាងជើងឲ្យសាវ័ករបស់ទ្រង់ ដែលវាជាការងាររបស់អ្នកបម្រើនោះទេ។ បន្ទាប់ពីបានធ្វើដូច្នេះហើយ ទ្រង់បានមានព្រះបន្ទូលដូចតទៅៈ

"តើអ្នករាល់គ្នាយល់អំពីកិច្ចការដែលខ្ញុំបានធ្វើ ចំពោះអ្នករាល់គ្នានេះឬទេ? អ្នករាល់គ្នាហៅខ្ញុំថា ព្រះគ្រូ និងព្រះអម្ចាស់ នោះត្រូវមែន គឺខ្ញុំហ្នឹងហើយ!។ បើខ្ញុំជាព្រះអម្ចាស់ និងជាព្រះគ្រូបាន លាងជើងអោយអ្នករាល់គ្នាទៅហើយ អ្នករាល់គ្នាក៏ត្រូវតែលាងជើងអោយគ្នាទៅវិញទៅមកដែរ។ ខ្ញុំបានធ្វើជាគំរូអោយអ្នករាល់គ្នាប្រព្រឹត្ត ដូចខ្ញុំបានប្រព្រឹត្តដល់អ្នករាល់គ្នា។ ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងច្បាស់ថា អ្នកបំរើមិនដែលធំជាងម្ចាស់ឡើយ រីឯអ្នកដែលគេចាត់អោយទៅ ក៏មិនដែលធំជាងអ្នកចាត់ខ្លួនអោយទៅនោះដែរ។ ប្រសិនបើអ្នករាល់គ្នាដឹងសេចក្ដីនេះហើយប្រតិបត្តិតាម អ្នករាល់គ្នាមុខជាមានសុភមង្គលមិនខាន។" (គម្ពីរយ៉ូហាន ១៣:១២-១៧)

លំហាត់អនុវត្តន៍

៣ តើប្រយោគណាខ្លះ នៅខាងក្រោមនេះស្របតាមអ្វីដែលព្រះយេស៊ូព្យាយាមបង្រៀនពួកសាវ័ករបស់ទ្រង់ (ព្រមទាំងពួកយើងផង) អំពីការស្វែងរកឋានៈ? ចូរគូសរង្វង់ជុំវិញអក្សរដែលនៅខាងមុខចម្លើយត្រឹមត្រូវ។

ក) ព្រះយេស៊ូគឺជាព្រះអម្ចាស់ និង ជាម្ចាស់។

ខ) ព្រះយេស៊ូបានលាងជើងសាវ័ករបស់ទ្រង់ ព្រោះទ្រង់ចង់បង្ហាញពួកគេ ថាទ្រង់បន្ទាបខ្លួនយ៉ាងណា?

គ) ព្រះយេស៊ូដែល ជាព្រះលើអស់ទាំងព្រះ បានធ្វើកិច្ចការបម្រើដ៏តូចទាប តាមរយៈការលាង ជើងសាវ័កទ្រង់។

ឃ) ទោះបីជាព្រះជាម្ចាស់អាចនឹងប្រើពួកសាវ័កតាមរបៀបដ៏អស្ចារ្យយ៉ាងណាក៏ដោយពួកគេមិនត្រូវមើលទៅលើខ្លួនឯងថាជាមនុស្សអស្ចារ្យនោះទេ ប៉ុន្តែជាមនុស្សអ្នកបម្រើ និង ជាអ្នកនាំសារបន្ទូលវិញ។

ង) ពួកសាវ័កត្រូវតែ សម្រេចឲ្យបាន ពិធីលាងជើងឲ្យអស់អ្នកដែលមានឋានៈក្រោមគេ ។

ច) ដោយស្គាល់ថា ខ្លួនគេគ្រាន់តែជាអ្នកបម្រើ និង ជាអ្នកនាំសារ ពួកសាវ័កគឺត្រូវធ្វើកិច្ចការរបស់អ្នកបម្រើទៅចំពោះគ្នាទៅវិញទៅមក។

ឆ) ព្រះយេស៊ូ បានសន្យាថា នឹងប្រទានពរឲ្យពួកគេ ប្រសិនបើពួកគេអាចលាងជើងឲ្យគ្នាទៅវិញទៅមក។

ជ) ព្រះយេស៊ូ បានសន្យាថា នឹងប្រទានពរឲ្យពួកគេ ប្រសិនបើពួកគេអាចធ្វើជាអ្នកបម្រើសម្រាប់គ្នាទៅវិញទៅមក។

មានមេរៀនពីរយ៉ាង យើងអាចរៀនបានពីចំណុចនេះ ដែលនឹងជួយយើងឲ្យយកឈ្នះលើបញ្ហានៃការថ្នាំងថ្នាក់ចិត្ត អំណួត និង អារម្មណ៍ខ្ពស់ជាងគេ ឬ អារម្មណ៍តូចទាបជាងគេ។

១. អស់អ្នកដែលមានតំណែងជាអ្នកដឹកនាំ គឺត្រូវដូចជាអ្នកបម្រើដែរ។ តំណែងរបស់ពួកគេ គួរតែជាមធ្យោបាយក្នុងការសរសើរតម្កើងព្រះគ្រិស្ត មិនមែនខ្លួនគេទេ។

២. អស់អ្នកដែលមានតំណែងតូចតាច ត្រូវតែបំពេញការងាររបស់ពួកគេ "ដូចធ្វើចំពោះព្រះអម្ចាស់" ដោយចាំថា ព្រះជាម្ចាស់គ្រប់គ្រងលើជីវិតរបស់ពួកគេ ហើយទ្រង់នឹងប្រទានពរឲ្យពួកគេ ប្រសិនបើពួកគេនៅរក្សាឥរិយាបថជាអ្នកបម្រើ ទោះបីជាកាលៈទេសៈនោះហាក់ដូចជាលំបាកយ៉ាងក៏ដោយ។ មិនថាអ្នកមានតំណែងអ្វីនោះទេ អ្នកត្រូវតែបំពេញការងារនោះឲ្យអស់ពីសមត្ថភាពរបស់អ្នក។

ជីវិតនៃការបម្រើ ដោយមិនខ្វល់ខ្វាយពីឋានៈ ជាគន្លឹះដែលនាំទៅរកការសប្បាយក្នុងចិត្ត និង ការផ្គាប់ព្រះទ័យព្រះអម្ចាស់។ បំណងចង់ក្លាយជាមនុស្សអស្ចារ្យជាងគេ គឺជា កម្លាំងបំផ្លិចបំផ្លាញមួយ។ វាបំផ្លាញសន្តិភាព ។ វាបំផ្លាញទំនាក់ទំនង។ វាបំផ្លាញការរួបរួមប្រកបជាមួយព្រះជាម្ចាស់។ សេរីភាពដ៏ពិតដើម្បីបង្ហាញពីព្រះគ្រិស្តឲ្យបានពេញលេញ បានមកនៅពេលដែលយើងសុខចិត្តលះបង់មហិច្ឆតាចង់បានឋានៈរបស់យើង នៅក្នុងលោកីយ៍នេះ។ រង្វាន់ពិតប្រាកដរបស់យើង មិនមែននៅក្នុងជីវិតមួយនេះទេ៖ "ព្រះអង្គប្រទានជីវិតអស់កល្បជានិច្ច ដល់អស់អ្នកដែលព្យាយាមប្រព្រឹត្តអំពើល្អ ហើយស្វែងរកសិរីរុងរឿងកិត្តិយស និងអ្វីៗដែលមិនចេះសាបសូន្យ" (គម្ពីរ រ៉ូម ២:៧) ។ ទ្រង់នឹងប្រទានសិរីរុងរឿង និង កិត្តិយស ដល់អ្នកណាដែលមានមហិច្ឆតាក្នុងការធ្វើល្អ។

លំហាត់អនុវត្តន៍

៤ ចូរអានគម្ពីរលូកា ១៧:៥-១០។ តើប្រយោគមួយណានៅខាងក្រោមនេះ ដែលបង្ហាញបានយ៉ាងច្បាស់អំពីអ្វីដែលព្រះយេស៊ូវបង្រៀននៅក្នុងរឿងមួយនេះ?

ក) វាគឺជារឿងធម្មតា ដែលយើងចង់បានការកោតសរសើរ សម្រាប់អ្វីដែលយើងបានធ្វើ ហើយយើងស័ក្តិសមទទួលបាន ការទទួលស្គាល់នៅពេលដែលយើងធ្វើការចែកទាន ។ នោះជាមូលហេតុដែលយើងចង់ជោគជ័យ។

ខ) នៅពេលដែលយើងធ្វើអ្វីដែលព្រះអម្ចាស់បញ្ជាឲ្យយើងធ្វើ យើងមិនគួរមើលឃើញតែការកោតសរសើរ និង ការតម្កើងខ្លួនឯងនោះទេ ប៉ុន្តែត្រូវប្រកាន់យកឥរិយាបថ "យើងខ្ញុំគ្រាន់តែជាអ្នកបំរើធម្មតាប៉ុណ្ណោះ គឺយើងខ្ញុំបានបំពេញកិច្ចការដែលយើងខ្ញុំត្រូវធ្វើ" វិញ។

គ) យើងមិនគួរទទួលស្គាល់ ឬលើកតម្កើងអស់អ្នកដែលធ្វើការចែកទាននោះទេ ព្រោះវានឹងធ្វើឲ្យពួកគេមានអារម្មណ៍ថាសំខាន់ និង ខ្ពង់ខ្ពស់ជាងគេ។

ប្រាកដណាស់ថា វាជារឿងធម្មតាដែលយើងចង់ទទួលបានការដឹងគុណនៅពេលដែលយើងធ្វើការងារបានល្អ ប៉ុន្តែបំណងចង់បានការកោតសរសើរ និង ការទទួលស្គាល់ មិនគួរជាការជំរុញចិត្តរបស់យើងក្នុងការធ្វើល្អនោះទេ។ម្យ៉ាងវិញទៀត អស់អ្នកដែលមានតំណែងជាអ្នកដឹកនាំ អាចកាត់បន្ថយ សក្តា

នុពលដែលបង្កឲ្យមានបញ្ហានេះបាន តាមរយៈការកោតសរសើរទៅតាមការសមគួរ។ ពាក្យលើកទឹកចិត្ត នឹងជំរុញចិត្តមនុស្សឲ្យប្រឹងប្រែងធ្វើការកាន់តែខ្លាំងឡើង និង ប្រកបដោយឥរិយាបថល្អ។

មិនមែនមនុស្សគ្រប់គ្នា អាចត្រូវបានត្រាស់ហៅឲ្យដឹកនាំនោះទេ។ ព្រះជាម្ចាស់នឹងមិន វិនិច្ឆ័យអ្នក តាមកម្រិតតំណែងរបស់អ្នកនោះទេ តែទៅតាមកម្រិតដែលអ្នកធ្វើកិច្ចការដែលជាតួនាទី*របស់អ្នក* បានល្អប៉ុនណា។ (សូមអានគម្ពីរម៉ាថាយ ២៥:១៤-៣០)

មានចម្រៀងមួយដែលមនុស្សភាគច្រើនធ្លាប់ស្គាល់ ច្រៀងថា៖ "ថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់ សម្រាប់អ្វីដែលទ្រង់បានធ្វើ" ។ តើអ្នកអាចនិយាយបានទេថា "ថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់ សម្រាប់អ្វីដែលខ្ញុំបានធ្វើ?"

គ. ភាពក្មេងខ្ចីរបស់គ្រិស្តបរិស័ទ

ទស្សតាងបង្ហាញពីភាពក្មេងខ្ចី

វត្ថុបំណងទី ៣. *រកឃើញដំណោះស្រាយសម្រាប់ភាពក្មេងខ្ចីរបស់គ្រិស្តបរិស័ទ នៅក្នុងគម្ពីរ អេភេសូជំពូក ៤ និង ជំពូក៥ ហើយសរសេរដំណោះស្រាយទាំងនោះនៅក្នុង តារាងមួយ។*

នៅពេលដែលអ្នកក្លាយជាគ្រិស្តបរិស័ទម្នាក់ អ្នកមិនបានបាត់បង់ភាពជាមនុស្សរបស់អ្នក បំណង ប្រាថ្នារបស់អ្នក អារម្មណ៍របស់អ្នក តម្រូវការរបស់អ្នក ឬ សមត្ថភាពក្នុងការឈឺចាប់នោះទេ ។ ទាំងនេះគឺ ជាអារម្មណ៍ដែលយើងត្រូវ ប្រឈមមុខជាមួយ ជារៀងរាល់ថ្ងៃនៅក្នុងទំនាក់ទំនងរបស់យើងជាមួយអ្នកដ ទៃ។ ការយកឈ្នះអារម្មណ៍ទាំងនេះបាន គឺទាមទារពេលវេលា វាជាដំណើរការនៃការពេញវ័យរបស់គ្រិស្តប រិស័ទ។ អ្នកប្រហែលជាបានស្គាល់អ្នកណាម្នាក់ ក៏ប្រហែលជាគ្រិស្តបរិស័ទម្នាក់ ដែលតែងតែចង់បានជួរ មុខគេ ដែលចង់បានកៅអីល្អបំផុត ដែលតែងតែមានអារម្មណ៍ត្រូវគេមើលងាយ ដែលនឹងរអ៊ូរទាំ រហូតគេ ទទួលបានអ្វីដែលល្អបំផុត។ នៅពេលដែលអ្វីៗកើតឡើងស្របទៅតាមការចង់បានរបស់គេ គេសប្បាយ ចិត្ត។ ពេលដែលមានបញ្ហាកើតឡើង ពួកគេមានការមិនពេញចិត្ត និង មួម៉ៅក្តៅក្រហាយ។

អ្នកក៏ប្រហែលជាធ្លាប់ស្គាល់គ្រិស្តបរិស័ទខ្លះ ដែលចំណាយពេលវេលារបស់គេ ខ្វល់ខ្វាយពីកូន របស់គេ អំពីភាពខ្វះខាតលុយកាក់ អំពីអ្វីដែលនឹងកើតឡើងនៅពេលដែលពួកគេចាស់ទៅ។ នេះគឺជា សញ្ញាមួយទៀតដែលបង្ហាញពីភាពក្មេងខ្ចីរបស់គ្រិស្តបរិស័ទ។

ខ្ញុំស្គាល់ស្ត្រីមេម៉ាយជាគ្រិស្តបរិស័ទម្នាក់ ដែលនាងរវល់ និង ធ្វើការងារជាច្រើន តែនៅពេលខ្លះនាង ក៏ប្រឈមមុខនឹងភាពឯកាដែរ។ តើគ្រិស្តបរិស័ទដែលពេញវ័យមានការតស៊ូប្រយុទ្ធដែរឬទេ? សំណួរនេះក៏ អាចយកទៅប្រើជាមួយនឹងអារម្មណ៍ភ័យខ្លាច ព្រួយបារម្ភ ការបាក់ទឹកចិត្ត ការសង្ស័យ ភាពអាត្មានិយម កំហឹង និង អារម្មណ៍របស់មនុស្សជាច្រើនផ្សេងៗទៀត។ សូម្បីតែ គ្រិស្តបរិស័ទពេញ វ័យ ក៏នៅតែតយុទ្ធ ជារៀងរាល់ថ្ងៃ ប៉ុន្តែពួកគេបានដឹងពីរបៀបយកឈ្នះបាន!

នៅក្នុងគម្ពីរអេភេសូជំពូក ៥ និង ជំពូក៦ លោកសាវ័កប៉ូលបានប្រឈមមុខនឹងការបង្ហាញឲ្យឃើញ ពីភាពក្មេងខ្ចី។ អ្នកនឹងសំគាល់ឃើញថា ភាពក្មេងខ្ចីភាគច្រើនគឺមានជាប់ទាក់ទងជាមួយនឹងទំនាក់ទំនង របស់យើងជាមួយអ្នកដទៃ។ លោកប៉ូលបាននិយាយទៅកាន់គ្រិស្តបរិស័ទ នៅក្នុងបទគម្ពីរមួយនេះ។

លោកបានព្រមានពួកគេមិនឲ្យបន្តរស់នៅក្នុងជីវិតដូចជាមនុស្សគ្មានសាសនានោះទេ។ បន្ទាប់មក ដើម្បីប្រាកដថាពួកគេអាចយល់អត្ថន័យអ្វីដែលលោកនិយាយបានពេញលេញ លោកបានផ្ដល់ឲ្យពួកគេនូវការណែនាំច្បាស់លាស់ អំពីរបៀបទទួលបានភាពពេញវ័យ។

លំហាត់អនុវត្តន៍

៥ ចូរអានគម្ពីរ អេភេសូជំពូក ៤ និង ជំពូក៥ ហើយបំពេញតារាងខាងក្រោមដោយ គិតជាមុនសិន ថាតើបញ្ហាដែលបានរៀបរាប់មកនោះ គឺជាបញ្ហាដែលអ្នកកំពុងប្រឈមដែរឬទេ។ បន្ទាប់ ចូរសរ សេរដំណោះស្រាយដែលលោកសាវ័កប៉ូលបានផ្ដល់ឲ្យសម្រាប់បញ្ហានីមួយៗ នៅក្នុងប្រអប់ ខាងស្ដាំ។យើងបាន ផ្ដល់ជូនដំណោះស្រាយទាំងនោះនៅខាងក្រោមតារាង។ ចូរស្វែងរកកន្លែង ស័ក្ដិសមសម្រាប់ដំណោះស្រាយនីមួយៗ ហើយសរសេរវានៅក្នុងប្រអប់ដែលត្រឹមត្រូវ។

ខគម្ពីរយោង	**ប្រសិនបើខ្ញុំមានបញ្ហានេះ**	**ខ្ញុំនឹងធ្វើដូច្នេះ៖**
គម្ពីរអេភេសូ ក) ៤:២៥	ការនិយាយកុហក	
ខ) ៤:២៦	កំហឹង	
គ) ៤:២៨	ការលួច	
ឃ) ៤:២៩	និយាយពាក្យអាក្រក់	
ង) ៤:៣០	ធ្វើអោយព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ ព្រួយព្រះហឫទ័យ	
ច) ៤:៣១-៣២; ៥:១-២	ចិត្តជូរចត់ ចិត្តក្ដៅក្រហាយ កំហឹង សំរែកឡូឡា ពាក្យជេរប្រមាថ ព្រមទាំងសេចក្ដីអាក្រក់គ្រប់បែបយ៉ាង	
ឆ) ៥:៣-៥	សូម្បីតែនិយាយអំពីការប្រាសចាកសីលធម៌អបាយមុខ ការលោភលន់ ឬ ពោលពាក្យទ្រគោះបោះបោក ពាក្យឡេះឡោះ ឬពាក្យអាសអាភាស	

ខគម្ពីរយោង	ប្រសិនបើខ្ញុំមានបញ្ហានេះ	ខ្ញុំនឹងធ្វើដូច្នេះ៖
ជ) ៥:៦-១១	ត្រូវបានមនុស្សអាក្រក់ នាំឲ្យប្រព្រឹត្តិអំពើបាប ត្រូវបានគេបោកបញ្ឆោត	
ឈ) ៥:១៥-១៦	មិនប្រុងប្រយ័ត្ន និង នៅរស់នៅក្នុងរបៀបមនុស្សឥតប្រាជ្ញា	
ញ) ៥:១៧	ធ្វើជាមនុស្សឥតគំនិត	
ដ) ៥:១៨	ស្រវឹងស្រា	

ដំណោះស្រាយ (លំដាប់លំដោយចម្លើយត្រូវបានច្របល់ចូលគ្នា។ ចូរស្វែងរកចម្លើយដែលស័ក្តិសម នៅក្នុងតារាងនីមួយៗ ហើយសរសេរលេខរៀងនៃចម្លើយនៅក្នុងប្រអប់ដែលត្រឹមត្រូវ។ ដំណោះស្រាយនីមួយៗត្រូវបានដកស្រង់ពីគម្ពីរអេភេសូជំពូក ៤ និងជំពូក៥ មក)។

១. កុំធ្វើអោយព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ ព្រួយព្រះហឫទ័យ។
២. កុំទាក់ទងជាមួយមនុស្សបែបនោះ។ ត្រូវបកអាក្រាតពួកគេ។
៣. ព្យាយាមស្វែងរកអ្វីដែលព្រះអម្ចាស់សព្វព្រះហឫទ័យឲ្យអ្នកធ្វើ។
៤. បំពេញគំនិតរបស់អ្នកដោយការសរសើរតម្កើង និង អរព្រះគុណ។
៥. មិនត្រូវធ្វើអំពើបាប។ មិនត្រូវប្រកាន់ខឹង។
៦. ត្រូវមានចិត្តសប្បុរស ចេះអាណិតមេត្តាដល់គ្នាទៅវិញទៅមក ត្រូវប្រណីសន្តោសគ្នាទៅវិញទៅមក ឲ្យសេចក្តីស្រឡាញ់ដឹកនាំ។
៧. មិនត្រូវស្រវឹងស្រា ប៉ុន្តែត្រូវពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ។
៨. និយាយតែសេចក្តីពិត
៩. ប្រើពាក្យល្អមានប្រយោជន៍។
១០. រស់នៅជាមនុស្សដែលមានប្រាជ្ញា ។ ប្រើប្រាស់ឱកាសទាំងប៉ុន្មានឲ្យមានប្រយោជន៍។
១១. ឈប់លួច ហើយចាប់ផ្តើមធ្វើការងារ។ ផ្គត់ផ្គង់ខ្លួនអ្នក និង ជួយដល់អ្នកក្រីក្រ។

មធ្យោបាយតែមួយគត់ដែលអ្នកអាចទទួលបាន ភាពពេញវ័យជាគ្រិស្តបរិស័ទ គឺត្រូវបានចាប់ផ្តើមធ្វើអ្វីដែលជួយអ្នកឲ្យពេញវ័យ។ ត្រូវអនុវត្តតាមរយៈដំណោះស្រាយដែលអ្នកដាក់នៅក្នុងជីវិតអ្នក។

ប្រភពដើម្បីទទួលបានភាពពេញវ័យ

វត្ថុបំណងទី៤. *ជ្រើសរើសប្រយោគដែលបកស្រាយបានយ៉ាងត្រឹមត្រូវ អំពីប្រភពដែលអាចឲ្យយើងមានភាពពេញវ័យនៅក្នុងព្រះគ្រិស្ត។*

ការលូតលាស់មិនមែនកើតឡើងដោយចៃដន្យនោះទេ។ ការលូតលាស់ មិនមែនជាផលដែលបានមកពីអ្វីដែលព្រះជាម្ចាស់ធ្វើសម្រាប់អ្នក ស្របពេលដែលអ្នកនៅអង្គុយមិនធ្វើអ្វីសោះនោះទេ។ ប្រភពថាមពលពីរយ៉ាងសម្រាប់ភាពពេញវ័យរបស់គ្រិស្តបរិស័ទ៖ ឫទ្ធានុភាពរបស់ព្រះជាម្ចាស់ និង *អំណាចនៃឆន្ទៈ* របស់អ្នកផ្ទាល់។

ឫទ្ធានុភាពរបស់ព្រះជាម្ចាស់

ប្រាកដណាស់ ឫទ្ធានុភាពរបស់ព្រះជាម្ចាស់គឺជាគ្រឹះដែលអំណាចឆន្ទៈរបស់អ្នកត្រូវតែពឹងផ្អែកលើ។ ការព្យាយាមធ្វើល្អ ដោយគ្មានការធ្វើឲ្យថ្មីនៅក្នុងព្រះគ្រិស្តជាមុន នោះយើងនឹងមិនអាចទទួលបានឥរិយាបថ ដែលលោកសាវ៉កប៉ូលបានលើកឡើងនៅក្នុងគម្ពីរអេភេសូជំពូក៤ និង ជំពូក៥ បានឡើយ។ សូមអានគម្ពីរអេភេសូ ៤:១៥-១៦ ម្តងទៀត។ ចំណាំថា ព្រះគ្រិស្តគឺជាសិរសា ។ ផ្នែកទាំងអស់នៃរូបកាយបានចុះសម្រុង និង ធ្វើជាមួយគ្នា *នៅក្រោមការគ្រប់គ្រងរបស់ទ្រង់។* នៅក្នុងគម្ពីរអេភេសូ ៤:២៣ អ្នកឃើញថា អ្នក "ត្រូវប្រែគំនិតប្រាជ្ញា និងវិញ្ញាណអោយបានថ្មីឡើង" ។ ចុងក្រោយ នៅក្នុងគម្ពីរអេភេសូ ៦:១០ លោកសាវ៉កប៉ូលប្រាប់យើងថា "ចូរទាញយកកម្លាំង ដោយរួមជាមួយព្រះអម្ចាស់ និងដោយសារព្រះចេស្តាដ៏ខ្លាំងក្លារបស់ព្រះអង្គ"។

ដូច្នេះ ដំបូងបង្អស់ គឺឫទ្ធានុភាពរបស់ព្រះជាម្ចាស់ហើយ ដែលប្រទានឲ្យយើងមានសមត្ថភាពក្នុងការរស់នៅសម្រាប់ទ្រង់ និង ធ្វើតាមអ្វីដែលយើងត្រូវបានបង្គាប់ឲ្យធ្វើនៅក្នុងគម្ពីរអេភេសូជំពូក៤ និង ជំពូក៥។

លំហាត់អនុវត្តន៍

៦ នេះគឺជារបៀបមួយទៀត ដើម្បីនិយាយពីជំហានដែលសំខាន់ជាងគេក្នុងការស្វែងរកដំណោះស្រាយសម្រាប់បញ្ហារបស់អ្នក (សូមមើលមេរៀនទី ២) ។ ព្រះជាម្ចាស់នឹងធ្វើឲ្យយើងបានថ្មីទាំងស្រុងនៅពេលដែលយើង

ក) ទទួលយកការណែនាំពីមិត្តភក្តិគ្រិស្តបរិស័ទ។

ខ) សារភាពបាប ទទួលជឿ និង ការធ្វើតាម ហើយដោះស្រាយបញ្ហាអំពើបាបមុនគេបង្អស់។

គ) ព្យាយាមធ្វើជាអ្នកជិតខាងដ៏ល្អ។

អំណាចឆន្ទៈ:

គម្ពីរអេភេសូ ៤:២៧ ចែងថា៖ "កុំហុចឱកាសអោយមារមកល្បួងបងប្អូន។" នេះបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ថា យើងអាចផ្តល់ឱកាសឲ្យមារល្បួងយើងបាន។ ចំណាំថា នៅក្នុងគម្ពីរអេភេសូជំពូក៤ និង ជំពូក៥ មានការណែនាំជាច្រើនចំពោះអ្វីដែលយើងត្រូវ *ធ្វើ*។ ព្រះជាម្ចាស់ទ្រង់មានកិច្ចការរបស់ទ្រង់ ហើយទ្រង់នឹងធ្វើកិច្ចការនោះដោយស្មោះត្រង់។ ប៉ុន្តែប្រសិនបើអ្នក និង ខ្ញុំមិនធ្វើកិច្ចការដែលជាចំណែករបស់យើងនោះទេ យើងនឹងមិនអាចលូតលាស់ទៅរកភាពពេញវ័យបានឡើយ ហើយយើងប្រហែលជាអាចបាត់បង់ទំនាក់ទំនងរបស់យើងជាមួយនឹងព្រះជាម្ចាស់ថែមទៀតផង។ យើងដាក់អំណាចនៃឆន្ទៈរបស់យើងឲ្យធ្វើការ ដោយ*ការស្តាប់បង្គាប់* តាមការណែនាំដែលប្រទានមកនៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់។ តាមរយៈការស្តាប់បង្គាប់នេះហើយ ដែលយើងអាចឆ្ពោះទៅដល់ភាពពេញវ័យរបស់គ្រិស្តបរិស័ទ និង ឈ្នះលើបញ្ហានៃភាពក្មេងខ្ចីបាន។

លំហាត់អនុវត្តន៍

---

៧ ចូរគូសរង្វង់ជុំវិញអក្សរដែលនៅពីមុខចម្លើយត្រឹមត្រូវ ដែលបង្ហាញពីប្រភពដើម្បីទទួលបានភាពពេញវ័យរបស់គ្រិស្តបរិស័ទ។

ក) ឫទ្ធានុភាពរបស់ព្រះជាម្ចាស់ដែលធ្វើឲ្យយើងបានថ្មីទាំងស្រុង មិនផ្អែកលើអាកប្បកិរិយារបស់យើងសូម្បីតែបន្តិច។

ខ) យើងប្រើអំណាចនៃឆន្ទៈរបស់យើងដើម្បីទទួលស្គាល់ព្រះគ្រិស្ត ជឿថាទ្រង់គឺជាព្រះអម្ចាស់ដ៏មានព្រះជន្មរស់របស់យើង និង ស្តាប់បង្គាប់តាមព្រះបញ្ជារបស់ទ្រង់។

គ) ការស្តាប់បង្គាប់ អាចកើតឡើងបាន ព្រោះមានឫទ្ធានុភាពរបស់ព្រះគ្រិស្តដែលនៅក្នុងយើង បន្ទាប់ពីទ្រង់បានធ្វើឲ្យយើងបានថ្មីទាំងស្រុង។

ឃ) បរាជ័យក្នុងការធ្វើតាមកិច្ចការដែលជាផ្នែករបស់យើង នឹងរារាំងយើងមិនឲ្យមានភាពពេញវ័យជាគ្រិស្តបរិស័ទបានឡើយ។

ង) ការស្តាប់បង្គាប់គឺជាគន្លឹះនាំទៅរកភាពពេញវ័យជាគ្រិស្តបរិស័ទ។

ច) បញ្ហាដែលកើតឡើងនៅក្នុងជីវិតរបស់គ្រិស្តបរិស័ទ គឺជាសញ្ញាបញ្ជាក់យ៉ាងច្បាស់អំពីភាពក្មេងខ្ចី។

លោកប៉ូលបានបន្តនៅក្នុងគម្ពីរអេភេសូជំពូក៦ ដើម្បីនិយាយពីអាវុធដែលយើងត្រូវការដើម្បីតយុទ្ធជាមួយភាពក្មេងខ្ចី។ *សេចក្តីពិត សេចក្តីសុចរិត* (ការរស់នៅត្រឹមត្រូវ) *ចិត្តប្រុងប្រៀបផ្សាយដំណឹងល្អ* (ទីបន្ទាល់របស់យើង) *ជំនឿ* និង *ព្រះបន្ទូលរបស់ព្រះជាម្ចាស់*។ ការណែនាំចុងក្រោយរបស់លោក គឺ ត្រូវ *អធិស្ឋាន* (គម្ពីរអេភេសូ ៦:១៨)។

ភាពពេញវ័យរបស់គ្រិស្តបរិស័ទ រួមមានដំណើរការនៃការលូតលាស់ទៅមុខជានិច្ច។ រាល់លើកដែលអ្នកធ្វើការសម្រេចចិត្ត ធ្វើតាមបង្គាប់របស់ព្រះជាម្ចាស់ អ្នកបានរីកលូតលាស់ខាងវិញ្ញាណអ្នក។

ឃ. ភាពមានបាន និង ភាពក្រីក្រ

វត្ថុបំណងទី៥. *ស្គាល់ដំណោះស្រាយនៅក្នុងព្រះគម្ពីរសម្រាប់បញ្ហាដែលទាក់ទងនឹង ភាពមានបាន និង ភាពក្រីក្រ។*

ប្រាក់ ហាក់ដូចជារបស់ដ៏ត្រឹមត្រូវមួយ។ វាអាចទិញសេចក្ដីសុខខាងរូបកាយ និង របស់ចាំបាច់នៅក្នុងជីវិតឲ្យយើងបាន ហើយវាអាចធ្វើរឿងល្អបាន ប្រសិនបើយើងប្រើវាឲ្យធ្វើ។ ប៉ុន្តែគម្ពីរ១ធីម៉ូថេ ៦:១០ បានព្រមានយើងថា៖ "ដ្បិតការស្រឡាញ់ប្រាក់ ជាឫសគល់នៃអំពើអាក្រក់គ្រប់បែបយ៉ាង។" ព្រះគម្ពីរបាននិយាយអំពីស្ថានសួគ៌តិចជាងនិយាយអំពីទ្រព្យសម្បត្តិដែលពេញដោយការបោកបញ្ឆោត និង ការល្បួងដ៏អាក្រក់របស់វា។

យើងបានរាប់បញ្ចូល ភាពមានបាន និង ភាពក្រីក្រនៅក្នុងបញ្ហានៅក្នុងទំនាក់ទំនងសង្គម ព្រោះមនុស្សជាច្រើនមានទោសកំហុសដោយការធ្វើអំពីអាក្រក់គ្រប់បែបយ៉ាងទាស់នឹងគ្នាទៅវិញទៅមក ដើម្បីគ្រាន់តែទទួលបានទ្រព្យសម្បត្តិខ្លួនគេ។ ប្រធានបទនេះ មានជាប់ទាក់ទងនឹង ការសិក្សារបស់យើងអំពីភាពលោភលន់ (សេចក្ដីលោភ) ដែលនៅមេរៀនមុន។ យើងមិនអាចនឹង រាប់បញ្ចូលការព្រមានទាំងអស់ដែលមាននៅក្នុងបទបន្ទូលទាំងប៉ុន្មានទាក់ទង បំណងប្រាថ្នាចង់មានបានរបស់យើង និង អារម្មណ៍ភ័យខ្លាចភាពក្រីក្ររបស់យើងនោះបានឡើយ ប៉ុន្តែយើងសង្ឃឹមថាអាចផ្ដល់ការណែនាំជាគោលខ្លះដែលនឹងជួយអ្នកជៀសវាងបញ្ហាដែលទាក់ទងជាមួយប្រាក់ និង ឥទ្ធិពលរបស់វាទៅលើទំនាក់ទំនងរបស់អ្នកជាមួយអ្នកដទៃ។ ដំបូង យើងនឹងនិយាយអំពីបញ្ហាដែលទាក់ទងជាមួយនឹង ភាពមានបាន និង ភាពក្រីក្រ។ បន្ទាប់មក យើងនឹងផ្ដល់ដំណោះស្រាយតាមព្រះគម្ពីរ សម្រាប់បញ្ហាទាំងនេះ ដែលដំណោះស្រាយទាំងអស់នោះមានទាក់ទងនឹងឥរិយាបថរបស់យើងទៅកាន់ប្រាក់ និង អ្វីដែលលុយអាចធ្វើសម្រាប់យើងបាន។

បញ្ហាដែលទាក់ទងទៅនឹងភាពមានបាន

១. *ភាពមានបានគាប់សង្កត់យើង។* បុរសអ្នកមាន វ័យក្មេងម្នាក់ដែលបានទូលសួរព្រះយេស៊ូអំពីរបៀបទទួលបានជីវិតអស់កល្បជានិច្ច បានចាកចេញដោយក្រៀមក្រំ ព្រោះគាត់ត្រូវបានគាប់សង្កត់ (ចងរឹតជាប់) ដោយភាពមានបានរបស់គាត់ ហើយគាត់មិនអាចលះបង់វាបានឡើយ (គម្ពីរ ម៉ាថាយ ១៩:១៦-២២)។ ពេលខ្លះ ផ្ទុយពីការគ្រប់គ្រងទ្រព្យសម្បត្តិ យើងត្រូវបានទ្រព្យសម្បត្តិគ្រប់គ្រងទៅវិញ ពេលវេលារបស់យើងទាំងអស់ត្រូវបានចំណាយទៅលើ ការថែរក្សាទ្រព្យសម្បត្តិរបស់យើង ឬ ការព្យាយាមរកទ្រព្យសម្បត្តិបន្ថែមទៀត។

២. *ភាពមានបានផ្ដល់អារម្មណ៍ខ្ពង់ខ្ពស់លើសគេ។* តាមរបៀបរបស់លោកីយ៍ គឺត្រូវលើកតម្កើងអ្នកមានឲ្យខ្ពង់ខ្ពស់ជាងគេ។ ជាញឹយៗ គ្រិស្តបរិស័ទក៏មានកំហុសដោយសារតែគេបានធ្វើរឿងដូចគ្នានេះដែរ។ ដោយមនុស្ស មើលទៅពួកគេជាមួយនឹងការលើកតម្កើងយ៉ាងខ្ពស់ ព្រមទាំងមានការកោតខ្លាចផងនោះ អ្នកមានទ្រព្យសម្បត្តិទាំងនោះ អាចគិតថាខ្លួនគេខ្ពង់ខ្ពស់ជាងអ្នកដទៃដែលមិនមានដល់គេ។

៣. *ភាពមានបានបំផ្លាញ ឬ ផ្លាស់ប្តូរគុណតម្លៃរបស់យើង* ។ វាងាយស្រួលណាស់ក្នុងការធ្លាក់នៅក្នុងអន្ទាក់នៃការឲ្យតម្លៃទ្រព្យសម្បត្តិ ជាងជីវិតខាងវិញ្ញាណ។ គ្រោះថ្នាក់នៃភាពមានបាន គឺជាទំនោរដែលទោរទៅរកការទុកចិត្តលើអ្វីដែលលុយអាចធ្វើបាន ជាជាងទុកចិត្តលើអ្វីដែលព្រះជាម្ចាស់ អាចធ្វើបាន។ លុយអាចធ្វើឲ្យអ្នកមានភាពងាយស្រួលខាងឯរូបកាយ ប៉ុន្តែវាមិនអាចសង្គ្រោះអ្នកបានឡើយ! ភាពមានបាន គឺពោរពេញដោយការបោកប្រាស់ (គម្ពីរម៉ាថាយ ១៣:២២) ។ ទ្រព្យសម្បត្តិមិននៅស្ថិតស្ថេរគង់វង្សរហូតទេ (គម្ពីរសុភាសិត ២៧:២៤) ។ សូមអានគម្ពីរ ទំនុកតម្កើង ៤៩ :១៦,២០; គម្ពីរម៉ាកុស ៤:១៩; គម្ពីរលូកា ៨:១៤; និង គម្ពីរលូកា ១២:១៨- ២១)។

លំហាត់អនុវត្តន៍

៨ ចូរជ្រើសរើសប្រយោគបំពេញដែលត្រឹមត្រូវ។ ខគម្ពីរខាងលើបានបង្ហាញឲ្យឃើញថា ភាពមានបានគឺពោរពេញដោយការបោកប្រាស់ ព្រោះវា

ក) មើលទៅហាក់បីដូចជាស្ថិតស្ថេរគង់វង្សណាស់ ប៉ុន្តែមិនមែនជាការពិតទេ។

ខ) អាចជឿលើអ្វី ដែលវាអាចនឹងធ្វើសម្រាប់យើងបាន។

គ) ធ្វើឲ្យយើងកាន់តែមានភាពងាយស្រួលខាងឯសាច់ឈាម។

---

៤. *ភាពមានបាននាំឲ្យមានការល្បួងឲ្យធ្វើអំពើបាប* ។ បុគ្គលម្នាក់អាចមានសីលធម៌ខ្ពស់ ប៉ុន្តែនៅ តែជាទាសករនៃសេចក្តីលោភលន់ និង មិនទទួលស្គាល់វាថាជាអំពើបាបទេ។ គម្ពីរអេភេសូ ៥:១-៦ ភ្ជាប់សេចក្តីលោភលន់ ជាមួយនឹងអំពីផឹតក្បត់។ ភាពលោភលន់ ដាក់លុយនៅកន្លែងដែលទុកសម្រាប់ព្រះជាម្ចាស់។ វាធ្វើឲ្យមនុស្សមិនស្មោះត្រង់ ក្នុងការទាក់ទងជាមួយអ្នកដទៃ និង ធ្វើការអាក្រក់ផ្សេងៗ ដូចជា រស់នៅក្នុងភាពស្តុកស្តម្ភ និង ការបណ្តោយខ្លួនយ៉ាងស្រួលនៅ លើការខាតបង់របស់អ្នកដទៃ ឬ មិនបង់ថ្លៃឈ្នួលដោយស្មោះត្រង់ និង ដល់ថ្នាក់ធ្វើឲ្យមនុស្សធ្វើទុក្ខទោស និង សម្លាប់មនុស្សដទៃទៀតផង (សូមមើលគម្ពីរយ៉ាកុប ៥:១-៦)។

បញ្ហាដែលទាក់ទងទៅនឹងភាពក្រីក្រ

ជាច្រើនលើកច្រើនសា ភាពក្រីក្រភ្ជាប់ជាមួយនឹងបញ្ហាដ៏ពិត ។ មនុស្សដែលគ្មានលុយគ្រប់គ្រាន់តែងតែមានបញ្ហា ដែលពួកគេអាចនឹងគិតពីខាងសាច់ឈាមជាងខាងវិញ្ញាណ។ ពិភពលោកមួយភាគធំត្រូវបានញាំញីដោយភាពក្រីក្រ និង ភាពភ័យខ្លាចសេចក្តីអត់ឃ្លានដែលនៅជាមួយគ្នានោះដែរ។

១. *ការព្រួយបារម្ភ និង ភាពភ័យខ្លាច* ។ ការព្រួយបារម្ភ និង ការភ័យខ្លាច ថាតើយើងអាចនឹងផ្គត់ផ្គង់តម្រូវការខ្លួនយើង ឬ គ្រួសាររបស់យើងដោយរបៀបណា គឺជាបញ្ហាដែលមនុស្សជាច្រើនមានដូចគ្នា រួមបញ្ចូលទាំងគ្រិស្តបរិស័ទផងដែរ។ យើងព្រួយបារម្ភអំពីការបាត់បង់ការការងាររបស់យើង អំពីការធ្លាក់ខ្លួនឈឺ និង មិនអាចធ្វើការបាន និងមិនមានប្រាក់គ្រប់គ្រាន់ដើម្បីបង់ថ្លៃចំណាយផ្សេងៗបាន។ នេះគឺជាការឆ្លើយតបធម្មតាទៅនឹងបញ្ហាដ៏ជាក់ស្តែងមួយ។

២. *ការល្បួងទៅរកសេចក្តីទុច្ចរិត*។ ទាំងអ្នកមាន និង អ្នកក្រ អាចត្រូវបានធ្វើទុក្ខដោយការល្បួង ឲ្យចង់បានទ្រព្យសម្បត្តិតាមរយៈអំពើទុច្ចរិត ប៉ុន្តែគេមានមូលហេតុផ្សេងពីគ្នា។ អ្នកក្រម្នាក់អាច រកលេសដើម្បីយកអ្វីម្យ៉ាងដែលជាកម្មសិទ្ធិថៅហ្វាយរបស់គាត់ អ្នកជិតខាងរបស់គាត់ ឬ ពីអ្នកមានណាម្នាក់។ ទោះជាយ៉ាងណា តម្រូវការរបស់គាត់ គឺចាំបាច់ជាងពួកអ្នកទាំងនោះ ។ ប៉ុន្តែក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ គិតសំដៅលើអំពើទុច្ចរិតទាំងអស់ មិនថាមូលហេតុអ្វីនោះទេ៖ "កុំលួចប្លន់គេ" (គម្ពីរនិក្ខមនំ ២០:១៥)។ អំពើទុច្ចរិតដែលធំជាងគេបំផុត ដែលឃើញមានទាំងនៅក្នុងចំណោមអ្នកមាន និង អ្នកក្រ គឺការកេងប្រវ័ញ្ចអ្វីដែលជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់៖ "តើមនុស្សកេងប្រវ័ញ្ចព្រះជាម្ចាស់ ដូចម្តេចបាន? អ្នករាល់គ្នាកេងប្រវ័ញ្ចយើង ហើយពោលថា "យើងខ្ញុំកេងប្រវ័ញ្ចព្រះអង្គដូចម្តេចខ្លះ?"។ គឺអ្នករាល់គ្នាកេងប្រវ័ញ្ច តង្វាយមួយភាគដប់ និង តង្វាយ ដែលអ្នករាល់គ្នាត្រូវញែកទុកសំរាប់យើង! (គម្ពីរម៉ាឡាគី ៣:៨)។

៣. *ការមានអារម្មណ៍ថា តូចទាបជាងគេ។* ដូចជាអ្នកមានដែលបានគិតថាខ្លួនគេ ខ្ពង់ខ្ពស់ជាងអ្នកដទៃដែរ អ្នកក្រក៏ចេះតែគិតថា ខ្លួនគេតូចទាប ដែលមានសមត្ថភាពអន់ជាងអ្នកដែលមានប្រាក់ច្រើនជាងខ្លួន។ ថ្វីដ្បិតតែ នេះគឺជាបញ្ហាដ៏ជាក់ស្តែងសម្រាប់មនុស្សជាច្រើន ប៉ុន្តែវាបានផ្អែកទៅលើគុណតម្លៃមួយដែលខុស ដូចដែលយើងបានដឹងស្រាប់ហើយ។

៤. *ការគិតខុសអំពីការផ្គត់ផ្គង់របស់ព្រះជាម្ចាស់*។ ដោយមានមូលហេតុមួយចំនួន ទោះបីជាមានការនិយាយអំពីភាពគ្រោះថ្នាក់របស់ភាពមានបាននៅក្នុងព្រះគម្ពីរយ៉ាងណាក៏ដោយ ក៏នៅមានមនុស្សជាច្រើន យល់ច្រលំថា ការគោរពកោតខ្លាចព្រះជាម្ចាស់នឹង ទទួលបានការរីកចម្រើនខាងហិរញ្ញវត្ថុទៅវិញ (គម្ពីរ ១ធីម៉ូថេ ៦:៥)។ ពួកគេតែងតែចែកចាយថា ប្រសិនបើអ្នកមានជំនឿគ្រប់គ្រាន់ អ្នកអាចក្លាយជាអ្នកមាន ឬប្រសិនបើអ្នកមិនក្លាយជាអ្នកមានទេ អ្នកបានធ្វើឲ្យខុសចំពោះព្រះជាម្ចាស់ដោយរបៀបណាមួយហើយ។ ពួកគេចូលទៅកាន់ព្រះជាម្ចាស់ជាមួយបំណងចិត្តដែលខុស គឺការស្វែងរកផលប្រយោជន៍ខាងឯសាច់ឈាមជាជាងប្រយោជន៍ខាងឯវិញ្ញាណ។ ព្រះគម្ពីរមានដំណោះស្រាយសម្រាប់គ្រប់បញ្ហាទាំងអស់ដែលយើងទើបនឹងបានសិក្សា។ នៅក្នុងលំហាត់បន្ទាប់ទៀតនេះ យើងនឹងផ្តល់ឱកាសឲ្យអ្នកស្វែងរក អ្វីដែលព្រះគម្ពីរនិយាយអំពីដំណោះស្រាយនីមួយៗ ដោយខ្លួនឯង។

លំហាត់អនុវត្តន៍

៩ នៅជួរខាងឆ្វេង យើងបានលើកឡើងបញ្ហាខ្លះៗ ជាមួយនឹងការរៀបរាប់មួយដែលផ្តល់ដំណោះស្រាយសម្រាប់បញ្ហានីមួយៗ។ នៅក្នុងជួរខាងស្តាំ យើងរៀបរាប់ខ្លីៗ អំពីបញ្ហាដែលអ្នកនឹងរកឃើញនៅក្នុងខគម្ពីរ។ ចូរផ្គូផ្គងដំណោះស្រាយនីមួយៗ (ជួរខាងស្តាំ) ជាមួយនឹងខគម្ពីរដែលទាក់ទងនឹងបញ្ហានោះ (ជួរខាងឆ្វេង)។ ចូរសរសេរលេខ នៃចម្លើយត្រឹមត្រូវនៅក្នុងចន្លោះបន្ទាត់។

........ក) ទាសករនៃភាពមានបាន៖ គម្ពីរម៉ាថាយ ១៩:២១-២២,២៩

........ខ) មានអារម្មណ៍ថាខ្ពង់ខ្ពស់ជាងគេ៖ គម្ពីរយ៉ាកុប ១:១០

........គ)ការផ្លាស់ប្តូរ និងការបំផ្លាញគុណតម្លៃ៖ គម្ពីរលូកា ១២:៣២-៣៤

.......ឃ) ការល្បួងឲ្យធ្វើអំពើបាប៖ គម្ពីរ១ធីម៉ូថេ ៦:៩-១១

........ង) ភាពភ័យខ្លាច និង ការព្រួយបារម្ភ៖ គម្ពីរម៉ាថាយ ៦:២៥-៣៤

........ច) ការល្បួងឲ្យធ្វើអំពើទុច្ចរិត៖ គម្ពីរអេសាយ ៣៣:១៥-១៦

.........ឆ) ការមានអារម្មណ៍ថាតូចទាបជាងគេ៖ គម្ពីរយ៉ាកុប ១:៩-១០

........ជ) ការគិតខុសអំពីការផ្គត់ផ្គង់របស់ព្រះជាម្ចាស់៖ គម្ពីរ១ធីម៉ូថេ ៦:៥-៨

១) ទុកចិត្តព្រះជាម្ចាស់ ស្វែងរកព្រះរាជ្យ និងភាពសុចរិតរបស់ទ្រង់ជាមុន ហើយទ្រង់នឹងផ្គត់ផ្គង់តម្រូវប្រចាំថ្ងៃរបស់អ្នក។

២) មនុស្សរបស់ព្រះជាម្ចាស់គួរជៀសឲ្យផុតពីបញ្ហានេះ ហើយតាមស្វែងរកអ្វីដែលជារបស់ព្រះជាម្ចាស់

៣) ត្រូវអរព្រះគុណព្រះជាម្ចាស់សម្រាប់តំណែងដ៏ខ្ពស់ជាកូនរបស់ព្រះជាម្ចាស់ និង ជាអ្នកបម្រើរបស់ទ្រង់។

៤) ត្រូវខ្វល់ខ្វាយពីរបស់ដែលមានគុណតម្លៃអស់កល្បជានិច្ច ជាងទ្រព្យសម្បត្តិនៅក្នុងលោកីយ៍ ដ្បិតទ្រព្យសម្បត្តិរបស់អ្នកនៅទីណា ចិត្តរបស់អ្នកនៅទីនោះ។

៥) ការគោរពកោតខ្លាចព្រះជាម្ចាស់គឺមិនផ្អែកទៅតាមទ្រព្យសម្បត្តិនៅលើផែនដីនោះទេ។

៦) ត្រូវដាក់ព្រះគ្រិស្ត និង អាណាចក្ររបស់ទ្រង់ជាទីមួយនៅក្នុងជីវិតរបស់អ្នក។

៧) ព្រះជាម្ចាស់នឹងប្រទាននំប៉័ង និង ទឹកឲ្យអ្នក។ (ទ្រង់នឹងប្រទានអ្វីទាំងអស់ដែលយើងត្រូវការ។)

៨) ចាត់ទុកខ្លួនអ្នកជា អ្នកបម្រើ ។ មិនត្រូវមានមោទនភាពជាមួយលុយរបស់អ្នកឡើយ តែជាមួយនឹងតំណែងតូចទាបរបស់អ្នកវិញ។

គុណតម្លៃរបស់គ្រិស្តបរិស័ទពាក់ព័ន្ធជាមួយនឹងលុយ

វត្ថុបំណងទី ៦. *ស្វែងរក និង កែកំហុសនៅក្នុងពាក្យមួយឃ្លាដែលនិយាយទាក់ទងនឹងគុណតម្លៃរបស់គ្រិស្តបរិស័ទពាក់ព័ន្ធជាមួយនឹងបញ្ហាលុយ។*

ទាំងនេះគឺជា ការណែនាំទូទៅ អំពីគុណតម្លៃដែលយើងគួរតែមាន ពាក់ព័ន្ធនឹង ទ្រព្យសម្បត្តិខាងសាច់ឈាម។ ការបង្កើតឥរិយាបថទាំងនេះបាន នឹងជួយអ្នកជៀសផុតពីគ្រោះថ្នាក់ដែលបណ្តាលមកពីលុយច្រើនពេក ឬ លុយតិចពេក។ ចូរអានបទគម្ពីរទាំងអស់ដែលបានផ្តល់ជូន។

១. *អ្នកគឺជាអ្នកមើលការខុសត្រូវលុយរបស់ព្រះជាម្ចាស់* (លូកា ១៦:១-១៣)។ គ្រិស្តបរិស័ទដែលមានការប្រុងប្រយ័ត្ន និងស្មោះត្រង់នៅក្នុងការងារពាក់ព័ន្ធជាមួយនឹងលុយ និង អ្នកដែលបានថ្វាយតង្វាយមួយភាគដប់នៃចំណូលរបស់គេទៅកាន់ព្រះជាម្ចាស់នឹងទទួលព្រះពរ (សូមមើលគម្ពីរម៉ាឡាគី ៣:៨-១១)។ ព្រះជាម្ចាស់បានតម្រូវថា ទ្រង់នឹងផ្គត់ផ្គង់តម្រូវការប្រចាំថ្ងៃរបស់យើង នៅពេលដែលយើងថ្វាយជីវិតរបស់យើងទៅកាន់ទ្រង់។ ប្រសិនបើ អ្នកគិតថា ខ្លួនអ្នកតែងតែមានតម្រូវខាងឯលុយកាក់ដើម្បីបំពេញតាមកាតព្វកិច្ចរបស់អ្នក ឬ ប្រសិនបើអ្នកតែងតែមានបញ្ហាជាបន្តបន្ទាប់ដូចជា ការចំណាយទាំងមិនបានព្រៀងទុក ជំងឺ ឬ បាត់បង់ការងារ ចូរអ្នកសួរខ្លួនឯងថា៖ "តើខ្ញុំជាអ្នកមើលខុសត្រូវលុយដ៏ស្មោះត្រង់របស់ព្រះជាម្ចាស់ឬទេ? តើខ្ញុំបានថ្វាយទៅទ្រង់ មួយភាគដប់នៃអ្វីដែលខ្ញុំជំពាក់ទ្រង់ហើយឬនៅ? តើខ្ញុំពិត ជាទុកចិត្តទ្រង់ក្នុងការផ្គត់ផ្គង់តម្រូវការរបស់ខ្ញុំដែរឬទេ?"

២. *កាតព្វកិច្ចរបស់ព្រះជាម្ចាស់ក្នុងការផ្គត់ផ្គង់តម្រូវការរបស់យើង គឺផ្អែកទៅលើការលះបង់របស់យើងសម្រាប់អាណាចក្ររបស់ទ្រង់*។ ព្រះជាម្ចាស់បានតម្រូវថា ទ្រង់នឹងប្រទានអ្វីៗគ្រប់យ៉ាងដែលយើងត្រូវការ។ នៅក្នុងគម្ពីរម៉ាថាយ ៦:២៥-៣៤ ព្រះយេស៊ូបានមានព្រះបន្ទូលប្រាប់យើងម្តងហើយម្តងទៀតថា៖ "កុំខ្វល់ខ្វាយ" ។ វាពិតជាអំពើឆោតល្ងង់មួយ បើខ្ញុំសរសេរដំណោះស្រាយបញ្ហានៅក្នុងមេរៀននេះយ៉ាងសាមញ្ញបំផុតថា "កុំខ្វល់ខ្វាយ" នោះ ព្រោះខ្ញុំគ្មានអំណាចអ្វី ដើម្បីបំពេញតម្រូវការរបស់អ្នកបានឡើយ ប៉ុន្តែយើងមានព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពដែលរក្សាព្រះបន្ទូលសន្យារបស់ទ្រង់។ នៅពេលដែលទ្រង់មានព្រះបន្ទូលថា ទ្រង់នឹងបំពេញតម្រូវការខាងសាច់ឈាមយើង ប្រសិនបើយើងព្យាយាមផ្គាប់ព្រះទ័យរបស់ទ្រង់ ។ ទ្រង់មានឫទ្ធានុភាពដើម្បីបំពេញតាមការសន្យានោះ ហើយទ្រង់នឹងធ្វើតាមការសន្យានោះដែរ។!

លំហាត់អនុវត្តន៍

១០ ចូរអានខគម្ពីរខាងក្រោម ហើយសរសេរការសន្យា ឬ កាតព្វកិច្ចដែលព្រះជាម្ចាស់បានធ្វើចំពោះអ្នក ទៅតាមខគម្ពីរនីមួយៗ។

ក) គម្ពីរភីលីព ៤:១៩...

ខ) គម្ពីរម៉ាថាយ ៦:២៥-៣៤..

គ) គម្ពីរហេប្រឺ ១៣:៥-៦...

---

១. *ទ្រព្យសម្បត្តិមិនអាចសង្គ្រោះអ្នកបានទេ។* ភាពមានបាននឹងក្លាយជាគ្មានតម្លៃនៅក្នុងថ្ងៃនៃការជំនុំជម្រះ (គម្ពីរសុភាសិត ១១:៤; គម្ពីរម៉ាថាយ ៦:១៩-២០)។

២. *ផលចំណេញដែលគ្រិស្តបរិស័ទគួរចាប់អារម្មណ៍គឺ ការគោរពកោតខ្លាចព្រះ និង ការសប្បាយចិត្ត* (គម្ពីរលូការ១២:១៥ , គម្ពីរ១ធីម៉ូថេ ៦:៦-៧)

៣. គុណតម្លៃដ៏ពិតខាងឯវិញ្ញាណគឺជាគុណតម្លៃដ៏អស់កល្បជានិច្ច (គម្ពីរកូឡូស ៣:១-៤)។

៤. *ចិត្តសប្បុរសឆ្ពោះទៅរកព្រះជាម្ចាស់គឺជាវិញ្ញាណត្រឹមត្រូវ សម្រាប់ទាំងអ្នកមាន និង អ្នកក្រ។* ព្រះជាម្ចាស់មិនត្រឹមតែរាប់អ្វីដែលអ្នកឲ្យនោះទេ ប៉ុន្តែទ្រង់ក៏រាប់ទាំងអ្វីដែលអ្នកនៅសេសសល់ទៀតផង។ ព្រះយេស៊ូបានមានព្រះបន្ទូលថា ស្ត្រីមេម៉ាយក្រីក្រម្នាក់ បានឲ្យច្រើនជាងអ្នកមានទាំងអស់នៅក្នុងព្រះវិហារ (គម្ពីរលូកា ២១:១-៤)។ លោកសាវ័កប៉ូលបាន និយាយសរសើរអ្នកក្រីក្រស្រុកម៉ាសេដូន ព្រោះមានអំណរខ្លាំងក្រៃលែង ហើយទោះបីគេក្រតោកយ៉ាកយ៉ាងណាក្តី ក៏គេនៅតែមានចិត្តសទ្ធាជ្រះថ្លាដ៏លើសលប់ដែរ" ហើយពួកគេថែមទាំងថ្វាយលើសពីសមត្ថភាពទៀតផង។ (គម្ពីរ២កូរិនថូស ៨:១-៥)។

លោកសាវ័កប៉ូលបាន រកឃើញថា នៅពេលដែលលោកបានថ្វាយជីវិតរបស់លោកទាំងស្រុងទៅព្រះយេស៊ូគ្រិស្ត អ្វីៗទាំងអស់ទទួលបានគុណតម្លៃថ្មីមួយ។ អ្វីដែលលោកធ្លាប់បានគិតថាមានសារៈសំខាន់ពីមុនមកគឺហាក់ដូចជាសម្រាម។ អ្វីដែលទាក់ទងនឹងព្រះគ្រិស្ត និង អំណាចនៃការរស់ឡើងវិញរបស់ព្រះអង្គ បានក្លាយទៅជារឿងសំខាន់លើសគេ (គម្ពីរភីលីព ៣:៧-១០)។ អ្នកជឿគ្រប់រូប នឹងដឹងថារឿងនេះជារឿងពិត។ យើងប្រើប្រាស់អ្វីៗដែលជារបស់លោកីយ៍ ប៉ុន្តែយើងមិនត្រូវបានស្រូបទាញឲ្យស្លុងចូលទៅក្នុងរបស់ទាំងនោះទេ(គម្ពីរ១កូរិនថូស ៧:៣១) ។ ការថ្វាយទៅកាន់ព្រះជាម្ចាស់ គឺជាអំណរ និងអភ័យឯកសិទ្ធិ ព្រោះទ្រង់យកបានកន្លែងទីមួយនៅក្នុងដួងចិត្តរបស់យើង។

លំហាត់អនុវត្តន៍

១១ ចូរអានប្រយោគនីមួយៗខាងក្រោមនេះ ដោយយកចិត្តទុកដាក់។ មានអ្វីម្យ៉ាងដែលមិនត្រឹមត្រូវនៅក្នុងប្រយោគទាំងអស់។ ចូរកែប្រយោគនីមួយៗ ដើម្បីឲ្យវាផ្តល់គុណតម្លៃដែលត្រឹមត្រូវមួយសម្រាប់គ្រិស្តបរិស័ទ ពាក់ព័ន្ធនឹងបញ្ហាលុយ។

ក) បរិមាណទ្រព្យសម្បត្តិដែលខ្ញុំមានក្នុងពេលនេះ នឹងមានតម្លៃខ្លាំងណាស់សម្រាប់ខ្ញុំ នៅថ្ងៃដែលព្រះជាម្ចាស់វិនិច្ឆ័យទោសខ្ញុំ។

....

....

ខ) ព្រះជាម្ចាស់ទាមទារឲ្យអ្នកមានធ្វើជាអ្នកទទួលខុសត្រូវដ៏ល្អសម្រាប់ទ្រព្យសម្បត្តិរបស់ទ្រង់។

....

....

គ) ព្រះជាម្ចាស់តម្រូវថាទ្រង់ត្រូវផ្គត់ផ្គង់តម្រូវការគ្រប់ទាំងអស់របស់មនុស្សគ្រប់គ្នា។

....

....

ឃ) យើងត្រូវដាក់ព្រះជាម្ចាស់ជាទីមួយ នៅក្នុងជីវិតរបស់យើង ដើម្បីឲ្យទ្រង់ថែរក្សាយើង។

....

....

ង) ចិត្តសប្បុរស គឺជាអ្វីម្យ៉ាងដែលមានតែអ្នកមានតែប៉ុណ្ណោះ អាចមាន។

....

....

ខ. ភាពអយុត្តិធម៌

វត្ថុបំណងទី៧. *ថ្លែងពីគោលការណ៍ដែលគួរតែដឹកនាំ ការឆ្លើយរបស់គ្រិស្តបរិស័ទម្នាក់ ដែលជាជនរងអំពើអយុត្តិធម៌។*

បញ្ហានៅក្នុងទំនាក់ទំនងសង្គម ដែលយើងបានពិភាក្សាមកដល់ចំណុចនេះ គឺមានទាក់ទងជាមួយនឹងឥរិយាបថ និង អាកប្បកិរិយារបស់យើង។ ឥឡូវនេះ យើងចង់និយាយអំពី បញ្ហាដែលយើងធ្លាប់ប្រឈមមុខ ហើយជាបញ្ហាដែលយើងមិនអាចគ្រប់គ្រងបាន ឬ គ្រប់គ្រងបានតិចតួច។ នោះគឺជា បញ្ហានៃភាពអយុត្តិធម៌៖ នៅពេលដែលនរណាម្នាក់ធ្វើអាក្រក់ ឬ ខុសឆ្គងមកលើអ្នក ទាំងដែលអ្នកមិនសមនឹងទទួលបានវាឡើយ។

ឧបមាថា អ្នកធ្វើកិច្ចព្រមព្រៀងជំនួញជាមួយនឹងបងប្អូនគ្រិស្តបរិស័ទម្នាក់ ដែលគាត់បានកេងចំណេញលើអ្នក ហើយគាត់មិនព្រមធ្វើវាឲ្យបានត្រឹមត្រូវវិញនោះទេ។ ឧបមាថា អ្នកប្រឹងប្រែងធ្វើការយ៉ាងខ្លាំង និងលើសពីអ្វីដែលថៅហ្វាយរបស់អ្នកដាក់ឲ្យទៀត ហើយស្រាប់តែមេការរបស់អ្នកបានយកគុណសម្បត្តិដែលបានមកពីការងារដែលលើសនោះ។ ក៏ប្រហែលជាអ្នកបានធ្វើការងារយ៉ាងល្អ ហើយមានមិត្តអ្នករួមការងារដែលមានចិត្តច្រណែនម្នាក់ បានរាយការណ៍ថា អ្នកបានមិនយកចិត្តទុកដាក់ ឬ ខ្ជិលនៅក្នុងការងាររបស់អ្នក។ ឬមានមិត្តភក្តិម្នាក់ដែលត្រូវបានគេតាមទាន់នៅពេលដែលកំពុងលួចចម្លងនៅក្នុងសាលា បានប្រាប់ទៅកាន់គ្រូថា អ្នកក៏បានលួចចម្លងដែរ ទោះបីជាជាក់ស្តែងអ្នកមិនបានធ្វើផង។ ប្រហែលជាមាននរណាម្នាក់ដែលមានសមត្ថភាពតិចជាងអ្នក ត្រូវបានតម្លើងឲ្យកាន់តំណែងខ្ពស់ ហើយអ្នកមានអារម្មណ៍ថា អ្នកស័ក្តិសមចំពោះតំណែងនោះជាង។

ខ្ញុំជឿថាអ្នកអាចគិតឃើញរឿងរ៉ាវជាច្រើនផ្សេងទៀត ទាក់ទងនឹងពេលដែលភាពអយុត្តិធម៌ បានកើតឡើងទាស់នឹងអ្នក។ សំណួរដែលសំខាន់នោះគឺ តើអ្នកឆ្លើយតបយ៉ាងដូចម្តេច? តើអ្នកមានអារម្មណ៍ខឹង និយាយពាក្យមិនល្អទៅកាន់អ្នកដែលបានធ្វើខុសចំពោះអ្នក មានអារម្មណ៍ចុះចាញ់ មានអារម្មណ៍ស្រណោះខ្លួនឯង ឬ ត្អូញត្អែរឲ្យគេស្តាប់ ឬ? វាគឺជារឿងធម្មតា ដែលអ្នកចង់ក្រោកឈរតស៊ូសម្រាប់ "សិទ្ធិ" របស់អ្នក សម្រាប់អ្វីដែលអ្នកមានសិទ្ធិទទួលបាន ។ តើគ្រិស្តបរិស័ទគួរតែឆ្លើយតបយ៉ាងដូចម្តេចទៅនឹងកាលៈទេសៈបែបនេះ? តើដំណោះស្រាយរបស់គ្រិស្តបរិស័ទទៅចំពោះបញ្ហានៃភាពអយុត្តិធម៌មានអ្វីខ្លះ?

ខ្ញុំមានមិត្តភក្តិម្នាក់ឈ្មោះប៉ូល ដែលគាត់ជាមន្ត្រីប៉ូលីសម្នាក់ ។ នៅពេលដែលគាត់បានក្លាយជាគ្រិស្តបរិស័ទម្នាក់ ភ្លាមៗនោះ ជីវិតរបស់គាត់គឺពោរពេញដោយសេចក្តីអំណរ ហើយគាត់ចង់ចែករំលែកបទពិសោធន៍នៅក្នុងព្រះគ្រិស្ត ជាមួយនឹងមនុស្សគ្រប់គ្នាដែលគាត់បានជួប។ គ្មានអ្វីអាចនឹងផ្លាស់ប្តូរឥរិយាបថរីករាយរបស់គាត់បានឡើយ មានតែលោកពលបាលត្រីម្នាក់ ដែលមានឋានៈលើគាត់។ មិត្តរបស់ខ្ញុំ តែងតែទៅធ្វើការជារៀងរាល់ព្រឹក ជាមួយចម្រៀងដែលច្រៀងនៅក្នុងចិត្តរបស់គាត់ គឺបានត្រឹមតែទទួលបានការស្វាគមន៍ ពីសំណាក់លោកពលបាលម្នាក់ដែលប្រកបដោយភាពល្វីងជូរចត់ កោងកាច ចាំតែចាប់កំហុស និងមិនសប្បាយចិត្ត ដែលព្យាយាមធ្វើឲ្យជីវិតរបស់ប៉ូលវេទនាទៅវិញ។ ការឆ្លើយតបរបស់លោកប៉ូល គឺត្រូវតែស្ងាត់ស្ងៀម ត្រូវបានដុតបញ្ឆេះជាមួយនឹងកំហឹងដែលនៅខាងក្នុងហើយមិននិយាយអ្វីទាំងអស់ ហើយព្យាយាមគិតពីមធ្យោបាយ "សងសឹក" មេរបស់គាត់។ ប៉ុន្តែក្នុងព្រឹកមួយ មានគំនិតមួយបានលេចឡើងចំពោះប៉ូល៖ "ហេតុអ្វីបានខ្ញុំអនុញ្ញាតឲ្យ*គាត់* ដកយកអំណរ និងជ័យជំនះរបស់ខ្ញុំយ៉ាងដូច្នេះ? ឥរិយាបថអាក្រក់របស់គាត់គឺជា *របស់គាត់* មិនមែនរបស់ខ្ញុំឯណា! ខ្ញុំនឹងអរសប្បាយនៅក្នុងព្រះអម្ចាស់ មិនថាលោកពលបាលនោះធ្វើអ្វីមកលើខ្ញុំនោះទេ!" ជាលទ្ធផល ប៉ូលចាប់ផ្តើមបង្ហាញសេចក្តីស្រឡាញ់ និង ចិត្តសប្បុរស ទៅចំពោះគាត់ ហើយដល់ពេលមួយ ប៉ូលបានយកគាត់ធ្វើជាមិត្តដ៏ល្អថែមទៀតផង។

ប៉ូលបានរៀនពីសេចក្តីពិតមួយដែលបានរៀបរាប់នៅក្នុង គម្ពីរម៉ាថាយ ៥:១០-១២៖
អ្នកណាត្រូវគេបៀតបៀន ព្រោះតែបានធ្វើតាមសេចក្ដីសុចរិត* អ្នកនោះមានសុភមង្គលហើយ ដ្បិតគេបានទទួលក្នុងព្រះរាជ្យ នៃស្ថានបរមសុខ! ប្រសិនបើមានគេត្មះតិះដៀល បៀតបៀន និងមានគេនិយាយអាក្រក់គ្រប់យ៉ាង បង្ខូចឈ្មោះអ្នករាល់គ្នា ព្រោះតែខ្ញុំ នោះអ្នករាល់គ្នាមានសុភមង្គលហើយ! ចូរអរសប្បាយរីករាយឡើង ព្រោះអ្នករាល់គ្នានឹងទទួលរង្វាន់យ៉ាងធំនៅស្ថានបរមសុខ ដ្បិតពួកព្យាការី*ដែលរស់នៅមុនអ្នករាល់គ្នា ក៏ត្រូវគេបៀតបៀនដូច្នោះដែរ។

បទគម្ពីរនេះបញ្ជាក់អំពីអ្វីដែលយើងបាននិយាយតាំងពីខាងដើមមេរៀននេះថា៖ យើងគឺជាឯកអគ្គរាជទូតរបស់ព្រះគ្រិស្ត ជាអ្នកតំណាងរបស់ទ្រង់ទៅកាន់លោកីយ៍។ អាកប្បកិរិយាល្អរបស់យើង នឹងទទួលបានការកោតសរសើរ និង ការគោរពសម្រាប់ព្រះវរបិតានាស្ថានបរមសុខ និង សម្រាប់ព្រះរាជរបស់ទ្រង់ផងដែរ។

ប្រាកដណាស់ មានពេលខ្លះ យើងអាចធ្វើការកែតម្រូវរឿងអយុត្តិធម៌ដែលបណ្ដាលមកពីការយល់ច្រលំ។ ប៉ុន្តែនៅពេលដែល មានរឿងអយុត្តិធម៌មួយកើតមានឡើង អ្នកអាចឆ្លើយតបតាមរបៀបដូចជាព្រះគ្រិស្ត គឺទទួលស្គាល់ថាបញ្ហានោះមិនមែនជាបញ្ហារបស់អ្នកទេ តែជារបស់អ្នកដទៃវិញ ហើយទទួលស្គាល់ថា អ្នកមានព្រះវរបិតានៃស្ថានបរមសុខ ដែលចាំមើលថែអ្នក ហើយនឹងផ្តល់ជ័យជម្នះនៅក្នុងដួងចិត្តរបស់អ្នក។ មានពេលខ្លះ ទ្រង់អនុញ្ញាតឲ្យអ្នកទ្រាំទ្រនឹងភាពអយុត្តិធម៌ ប៉ុន្តែទ្រង់នឹងប្រើប្រាស់វាដើម្បីផលប្រយោជន៍ដ៏អស់កល្បជានិច្ច។

លំហាត់អនុវត្តន៍

១២ ចូរប្រាប់អំពីគោលការណ៍ដែលអាចនឹងជួយដឹកនាំការឆ្លើយតបរបស់គ្រិស្តបរិស័ទ ដែលជាជន រងគ្រោះនៅក្នុងភាពអយុត្តិធម៌។

....

....

ខ្ញុំមិនអាចគិតឃើញពីការសន្និដ្ឋានណាមួយសម្រាប់មេរៀនមួយនេះ ក្រៅតែពីជំរុញអ្នកឲ្យអានគម្ពីររ៉ូមជំពូក១២ ដោយយកចិត្តទុកដាក់ និង ដោយការសញ្ជឹងគិតពិចារណា។ ជំពូកនេះ បានផ្តល់នូវខគម្ពីរដែលជាការណែនាំយ៉ាងពេញលេញ សម្រាប់អស់អ្នកដែលចង់មានទំនាក់ទំនងត្រឹមត្រូវជាមួយព្រះជាម្ចាស់ និង ជាមួយអ្នកដទៃ។ ចូរអានបទគម្ពីរឲ្យបានញឹកញាប់ ហើយអនុញ្ញាតឲ្យបទគម្ពីរនេះធ្វើជាមគ្គុទេសក៍សម្រាប់ទំនាក់ទំនងទាំងអស់របស់អ្នក។

លំហាត់អនុវត្តន៍

១៣ មុនពេលដែលអ្នកធ្វើការប្រឡងផ្ទាល់ខ្លួន ចូររំឭកអំពីបញ្ហាផ្សេងៗ នៅក្នុងទំនាក់ទំនងសង្គម។ ចូរគូសសំគាល់ បញ្ហាដែលអ្នកទើបនឹងឆ្លងកាត់ថ្មីៗ នៅក្នុងតារាងដែលបានផ្តល់ជូន។ បន្ទាប់មក សូមបកត្រឡប់ទៅមេរៀនទី ១ ដល់ ទី៣ ហើយយកគោលការណ៍សម្រាប់ការដោះស្រាយបញ្ហារបស់គ្រិស្តបរិស័ទមកអនុវត្ត ដើម្បីស្វែងរកដំណោះស្រាយសម្រាប់បញ្ហានីមួយៗ។ ត្រូវតែប្រាកដថា ដំណោះស្រាយរបស់អ្នក ផ្អែកទៅលើបទគម្ពីរ។ គោលបំណងរបស់យើង នៅក្នុងការបង្កើតលំហាត់នេះឡើង គឺជួយអ្នកឲ្យអនុវត្តតាមគោលការណ៍ដែលបានបង្រៀននៅក្នុងមេរៀននេះដោយផ្ទាល់ ដើម្បីឲ្យអ្នកអាចទទួលបានគុណសម្បត្តិ។ យើងជឿថាអ្នកនឹងធ្វើលំហាត់ប្រកបដោយបំណងចិត្តស្មោះត្រង់ ក្នុងការស្វែងរកដំណោះស្រាយសម្រាប់បញ្ហាដែលអាចកើតមាន នៅក្នុងជីវិតរបស់អ្នក។

នៅក្នុងមេរៀនបន្ទាប់របស់យើង យើងនឹងពិភាក្សាអំពីបញ្ហានៅក្នុងទំនាក់ទំនងគ្រួសារ។ មេរៀននេះគឺជាផ្នែកមួយនៃការយកចិត្តទុកដាក់យ៉ាងចាំបាច់សម្រាប់គ្រិស្តបរិស័ទគ្រប់រូប។ សូមព្រះអម្ចាស់ប្រទានពរអ្នក នៅពេលដែលអ្នកបន្តការសិក្សាទៅមុខទៀត។

ការប្រឡងផ្ទាល់ខ្លួន

សំណួរពហុជម្រើស៖ មានចម្លើយត្រឹមត្រូវមួយសម្រាប់សំណួរខាងក្រោម។ ចូរគូសរង្វង់ជុំវិញអក្សរនៃចម្លើយត្រឹមត្រូវ។

១ ភាពលោភលន់គឺជា

ក) ស្មោះត្រង់។

ខ) ការប្រៀបធៀបខ្លួនឯងជាមួយអ្នកដទៃ។

គ) ការចង់បានអ្វីដែលជារបស់អ្នកដទៃ។

ឃ) ព្យាយាមឲ្យបានល្អជាងគេ។

២ ព្រះយេស៊ូបានលាងជើងពួកសាវ័ករបស់ទ្រង់ ដើម្បីបង្ហាញពួកគេថាពួកគេត្រូវមានព័ន្ធកិច្ចនៃ

ក) ការបម្រើគ្នាទៅវិញទៅមក។

ខ) ភាពជាអ្នកដឹកនាំ។

គ) ភាពអស្ចារ្យជាងគេ។

ឃ) ឋានៈខ្ពស់។

៣ តើអ្វី ដែលផ្តល់គ្រឹះមូលដ្ឋានសម្រាប់ភាពពេញវ័យរបស់គ្រិស្តបរិស័ទ។

ក) ការលន់តួបាប

ខ) អំណាចនៃឆន្ទៈ

គ) ការពង្រឹងកម្លាំងរបស់អ្នក

ឃ) ឫទ្ធានុភាពរបស់ព្រះជាម្ចាស់។

៤ តើចម្លើយណាមួយនៅខាងក្រោមនេះ មិនមែនជាបញ្ហាដែលមិនសូវទាក់ទងជាមួយនឹងទ្រព្យសម្បត្តិ?

ក) មានអារម្មណ៍ខ្ពង់ខ្ពស់ជាងគេ

ខ) មានអារម្មណ៍តូចទាបជាងគេ។

គ) ការបំផ្លាញគុណតម្លៃ

ឃ) សេចក្តីល្បួងឲ្យធ្វើអំពើបាប។

៥ ទ្រព្យសម្បត្តិ គឺពេញដោយការបោកបញ្ឆោត ព្រោះទ្រព្យសម្បត្តិមិន

ក) ស្ថិតស្ថេរគង់វង្សទេ។

ខ) ចេះស្កប់ស្កល់ទេ។

គ) នាំឲ្យមានភាពសប្បាយរីករាយទេ។

ឃ) ធ្វើឲ្យអ្នកមានអារម្មណ៍ថាសំខាន់ទេ។

៦ ដំណោះស្រាយចំពោះភាពលោភលន់គឺ សេចក្តីស្រឡាញ់ ព្រោះសេចក្តីស្រឡាញ់
 ក) មិនមែនជាការអួត។
 ខ) ជាការទុកចិត្ត។
 គ) ជាការអត់ធ្មត់។
 ឃ) គឺមិនច្រណែន។

៧ គ្រិស្តបរិស័ទនឹងមិនស្វែងរកឋានៈ និង ការទទួលស្គាល់សម្រាប់ខ្លួន ប្រសិនជាគេចាត់ទុក តំណែងរបស់ពួកគេជា មូលហេតុក្នុងការ
 ក) ទទួលបានអំណាច
 ខ) សរសើរតម្កើងព្រះគ្រិស្ត
 គ) បន្ទាបខ្លួន
 ឃ) ដាក់ខ្លួន

៨ ដើម្បីធ្វើជាអ្នកទទួលខុសត្រូវដ៏ល្អសម្រាប់ទ្រព្យសម្បត្តិរបស់ព្រះជាម្ចាស់ អ្នកត្រូវ
 ក) យកឲ្យច្រើនតាមតែអាចធ្វើទៅបាន។
 ខ) មានអ្វីៗទាំងអស់ដែលអ្នកចង់បាន។
 គ) លក់អ្វីៗទាំងអស់ដែលអ្នកមានហើយចែកទានឲ្យអ្នកក្រ។
 ឃ) ដាក់ព្រះរាជ្យរបស់ព្រះជាម្ចាស់ជាទីមួយ ហើយចែកទានជាមួយនឹងចិត្តសប្បុរស។

៩ តួនាទីរបស់ព្រះជាម្ចាស់ក្នុងការផ្គត់ផ្គង់តម្រូវការរបស់អ្នក គឺផ្អែកទៅលើ
 ក) ឫទ្ធានុភាពរបស់ទ្រង់ក្នុងការផ្គត់ផ្គង់។
 ខ) ភាពចាំបាច់នៃតម្រូវការរបស់អ្នក។
 គ) ការប្តេជ្ញាចិត្តរបស់អ្នកទាំងស្រុងទៅចំពោះព្រះរាជ្យរបស់ព្រះជាម្ចាស់។
 ឃ) ថាតើអ្នកបារម្ភពីតម្រូវការនោះដែរ ឬទេ។

១០ ដំណោះស្រាយរបស់គ្រិស្តបរិស័ទទៅចំពោះភាពអយុត្តិធម៌គឺ
 ក) ទទួលយកភាពអយុត្តិធម៌តាមរបៀបដូចជាព្រះគ្រិស្ត ហើយទុកចិត្តថាព្រះជាម្ចាស់នឹងប្រទានឲ្យអ្នកមានជ័យជម្នះលើភាពអយុត្តិធម៌នោះ។
 ខ) អធិស្ឋានសូមឲ្យព្រះជាម្ចាស់ដាក់ទោស អ្នកដែលបានធ្វើខុសមកលើអ្នក។
 គ) ក្រោកឈរតស៊ូសម្រាប់សិទ្ធិរបស់អ្នក។
 ឃ) សងសឹកអ្នកដែលបានធ្វើខុសមកលើអ្នក។

ត្រូវ/ខុស។ ចូរសរសេរអក្សរ ត នៅក្នុងចន្លោះបន្ទាត់ ប្រសិនបើចម្លើយត្រឹមត្រូវ និងសរសេរអក្សរ ខ បើចម្លើយខុស។

........១១ ព្រះយេស៊ូបានបង្រៀនថា អ្នកណាដែលបម្រើ គួរតែមានលក្ខណៈដូចជា អ្នកគ្រប់គ្រង។

........១២ កម្រិតនៃការខិតខំប្រឹង ដែលមនុស្សម្នាក់គួរដាក់ទៅលើការងារមួយ គឺផ្អែកទៅលើសារៈសំខាន់នៃការងារនោះ។

........១៣ អ្នកបម្រើដ៏ពិតម្នាក់គឺជាម្នាក់ដែលនិយាយថា ៖ "យើងខ្ញុំបានបំពេញកិច្ចការដែលយើងខ្ញុំត្រូវធ្វើ"។

........១៤ ការសរសើរនរណាម្នាក់ នៅពេលដែលគេធ្វើការងារបានល្អ គឺជារឿងមិនត្រឹមត្រូវ។

........១៥ គ្រិស្តបរិស័ទដែលពេញវ័យ គឺបានរួចផុតពីបញ្ហាទាំងអស់។

........១៦ មធ្យោបាយដែលល្អបំផុតដើម្បីទទួលបានភាពពេញវ័យជាគ្រិស្តបរិស័ទ គឺត្រូវចាប់ផ្តើមធ្វើអ្វីៗ ដែលនឹងជួយអ្នកបានពេញវ័យ។

........១៧ ព្រះជាម្ចាស់បានប្រទានរឿងជាច្រើនដែលយើងត្រូវធ្វើដើម្បីទទួលបានភាពពេញវ័យជាគ្រិស្តបរិស័ទ។

........១៨ យើងប្រើអំណាចនៃឆន្ទៈឲ្យមានប្រយោជន៍តាមរយៈការស្តាប់បង្គាប់។

........១៩ ភាពគ្រោះថ្នាក់របស់ទ្រព្យសម្បត្តិ គឺថា យើងអាចនឹងទុកចិត្តវាជាងទុកចិត្តព្រះជាម្ចាស់។

........២០ ប្រសិនបើអ្នកមានជំនឿគ្រប់គ្រាន់ អ្នកអាចក្លាយជាអ្នកមានបាន។

ចម្លើយលំហាត់អនុវត្តន៍

៧ ក) ខុស

ខ) ត្រូវ

គ) ត្រូវ

ឃ) ត្រូវ

ង) ត្រូវ

ច) ខុស (ចំពោះបញ្ហាខ្លះ តែមិនប្រាកដថាទាំងអស់នោះទេ)។

១ *សេចក្តីស្រឡាញ់* គឺជាដំណោះស្រាយ ហើយ បទគម្ពីរយោងគឺ ១កូរិនថូសជំពូក១៣។ (ស្រឡាញ់តែងតែអត់ធ្មត់ ជួយធុរៈគេ ហើយមិនចេះឈ្នានីសគេទេ។ អ្នកមានចិត្តស្រឡាញ់មិនវាយឫកខ្ពស់ មិនអួតបំប៉ោងឡើយ។ អ្នកមានចិត្តស្រឡាញ់ មិនប្រព្រឹត្តអំពើថោកទាប មិនស្វែងរកប្រយោជន៍ផ្ទាល់ខ្លួន មិនមួម៉ៅ មិនចងគំនុំ មិនអបអរនឹងអំពើទុច្ចរិតទេ តែរីករាយនឹងសេចក្តីពិតវិញ។ អ្នកមានចិត្តស្រឡាញ់ អត់ឱនអោយទាំងអស់ ជឿទាំងអស់ សង្ឃឹមទាំងអស់ ហើយទ្រាំទ្រទាំងអស់។សេចក្តីស្រឡាញ់មិនសាបសូន្យសោះឡើយ។)

៨ ក) មើលទៅហាក់បីដូចជាស្ថិតស្ថេរគង់វង្សណាស់ ប៉ុន្តែមិនមែនជាការពិតទេ។

២ តើចម្លើយរបស់អ្នកបង្ហាញឲ្យឃើញពីបញ្ហាណាមួយជាមួយនឹងភាពលោភលន់នៅក្នុងជីវិតរបស់អ្នកដែរឬទេ? ប្រសិនបើមាន ខ្ញុំសូមណែនាំឲ្យអ្នក ធ្វើតាមជំហានក្នុងការដោះស្រាយបញ្ហាជាមួយចិត្តស្មោះត្រង់ ដើម្បីកែតម្រូវបញ្ហានេះ និង បង្កើតឥរិយាបថដែលត្រឹមត្រូវផងដែរ។ ជំហានទាំងនេះមានផ្តល់ជូនរួចហើយ នៅក្នុងមេរៀនទី៣។

៩ ក) ៦) ត្រូវដាក់ព្រះគ្រិស្ត និង អាណាចក្ររបស់ទ្រង់ជាទីមួយនៅក្នុងជីវិតរបស់អ្នក។

ខ) ៨) ចាត់ទុកខ្លួនអ្នកជា អ្នកបម្រើ ។ មិនត្រូវមានមោទនភាពជាមួយលុយរបស់អ្នកឡើយ តែជាមួយនឹងតំណែងតូចទាបរបស់អ្នកវិញ។

គ) ៤) ត្រូវខ្វល់ខ្វាយពីរបស់ដែលមានតម្លៃអស់កល្បជានិច្ច ជាងទ្រព្យសម្បត្តិនៅក្នុងលោកីយ៍ ដ្បិតទ្រព្យសម្បត្តិរបស់អ្នកនៅទីណា ចិត្តរបស់អ្នកនៅទីនោះ។

ឃ) ២) មនុស្សរបស់ព្រះជាម្ចាស់គួរជៀសឲ្យផុតពីបញ្ហានេះ ហើយតាមស្វែងរកអ្វីដែលជារបស់ព្រះជាម្ចាស់។

ង) ១) ទុកចិត្តព្រះជាម្ចាស់ ស្វែងរកព្រះរាជ្យ និង ភាពសុចរិតរបស់ទ្រង់ជាមុន ហើយទ្រង់នឹងផ្គត់ផ្គង់តម្រូវការប្រចាំថ្ងៃរបស់អ្នក។

ច) ៧) ព្រះជាម្ចាស់នឹងប្រទាននំបុ័ង និង ទឹកឲ្យអ្នក។ (ទ្រង់នឹងប្រទានអ្វីៗទាំងអស់ដែលយើងត្រូវការ។)

ឆ) ៣) ត្រូវអរព្រះគុណព្រះជាម្ចាស់សម្រាប់តំណែងដ៏ខ្ពស់ជាកូនរបស់ព្រះជាម្ចាស់ និង ជាអ្នកបម្រើរបស់ទ្រង់។

ដ)	៥)	ការគោរពកោតខ្លាចព្រះជាម្ចាស់គឺមិនផ្អែកទៅតាមទ្រព្យសម្បត្តិនៅលើផែនដីនោះទេ។

៣	ក), គ), ឃ), ច) និង ជ) ជាចម្លើយត្រឹមត្រូវ។

១០	ក)	ទ្រង់នឹងបំពេញតម្រូវការរបស់អ្នក។

ខ)	ប្រសិនបើអ្នកដាក់ព្រះរាជ្យព្រះជាម្ចាស់ជាទីមួយនៅក្នុងជីវិតរបស់អ្នក ទ្រង់នឹង ប្រទានអ្វីទាំងអស់ដែលអ្នកត្រូវការ។

គ)	ទ្រង់នឹងមិនទុកអ្នកចោល និង មិនបោះបង់អ្នកចោលឡើយ។

៤	ចម្លើយ ខ) បង្ហាញពីអ្វីដែលព្រះយេស៊ូបានបង្រៀនយ៉ាងច្បាស់លាស់។ ប្រយោគពីរផ្សេងទៀតគឺតំណាងឲ្យឥរិយាបថរឹងចចេស និង ខុសឆ្គង។

១១	ក)	បរិមាណទ្រព្យសម្បត្តិដែលខ្ញុំមានក្នុងពេលនេះ នឹងគ្មានតម្លៃអ្វីសម្រាប់ខ្ញុំ នៅថ្ងៃដែល ព្រះជាម្ចាស់វិនិច្ឆ័យទោសខ្ញុំនោះទេ។

ខ)	ព្រះជាម្ចាស់ទាមទារឲ្យទាំងអ្នកមាន និង អ្នកក្រធ្វើជាអ្នកទទួលខុសត្រូវដ៏ល្អសម្រាប់ទ្រព្យសម្បត្តិរបស់ទ្រង់។

គ)	ព្រះជាម្ចាស់តម្រូវថាទ្រង់ត្រូវផ្គត់ផ្គង់តម្រូវការរបស់អ្នកណាដែលទុកព្រះរាជ្យរបស់ព្រះអង្គជាទីមួយនៅក្នុងជីវិតរបស់គេ។

ឃ)	យើងត្រូវដាក់ព្រះជាម្ចាស់ជាទីមួយ នៅក្នុងជីវិតរបស់យើង បន្ទាប់មកទុកចិត្តថាទ្រង់នឹងថែរក្សាយើង។

ង)	គ្រិស្តបរិស័ទទាំងអស់ ទាំងអ្នកមាន និង អ្នកក្រ ត្រូវតែមានចិត្តសប្បុរស។

៥	ក)	៨.	និយាយតែសេចក្តីពិត

ខ)	៥.	មិនត្រូវធ្វើអំពើបាប។ មិនត្រូវប្រកាន់ខឹង។

គ)	១១.	ឈប់លួច ហើយចាប់ផ្តើមធ្វើការងារ។ ផ្គត់ផ្គង់ខ្លួនអ្នក និង ជួយដល់អ្នកក្រីក្រ។

ឃ)	៩.	ប្រើពាក្យល្អមានប្រយោជន៍។

ង)	១.	កុំធ្វើអោយព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ ព្រួយព្រះហឫទ័យ។

ច)	៦.	ត្រូវមានចិត្តសប្បុរស ចេះអាណិតមេត្តាដល់គ្នាទៅវិញទៅមក ត្រូវប្រណីសន្តោសគ្នាទៅវិញទៅមក ឲ្យសេចក្តីស្រឡាញ់ដឹកនាំ។

ឆ)	៤.	បំពេញគំនិតរបស់អ្នកដោយការសរសើរតម្កើង និង អរព្រះគុណ។

ជ)	២.	កុំទាក់ទងជាមួយមនុស្សបែបនោះ។ ត្រូវបកអាក្រាតពួកគេ។

ឈ)	១០.	រស់នៅជាមនុស្សដែលមានប្រាជ្ញា ។ ប្រើប្រាស់ឱកាសទាំងប៉ុន្មានឲ្យមានប្រយោជន៍។

ញ)	៣.	ព្យាយាមស្វែងរកអ្វីដែលព្រះអម្ចាស់សព្វព្រះហឫទ័យឲ្យអ្នកធ្វើ។

ដ)	៧.	មិនត្រូវស្រវឹងស្រា ប៉ុន្តែត្រូវពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធវិញ។

១២ ចម្លើយរបស់អ្នក។ ចម្លើយនោះគួរតែរួមបញ្ចូលគោលគំនិតនេះផង៖ គ្រិស្តបរិស័ទអាចឆ្លើយតបតាមរបៀបដូចជាព្រះគ្រិស្ត ទៅចំពោះភាពអយុត្តិធម៌ ដោយចងចាំថា ពួកគេជាអ្នកតំណាងព្រះវរបិតានៃស្ថានបរមសុខរបស់ពួកគេ ដែលទ្រង់ចាំមើលថែរក្សាពួកគេជានិច្ច។

៦ ខ) សារភាពបាប ទទួលជឿ និង ការធ្វើតាម ហើយដោះស្រាយបញ្ហាអំពើបាបមុនគេបង្អស់។

១៣ ចម្លើយរបស់អ្នក។